មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ សក់ ស៊ីម ភេទប្រុស អាយុ៦៧ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ គណៈយោធាកងពល៨០១**

**ស្រុកកំណើតនៅភូមិព្រៃអំពាវ ឃុំស្ដុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ**

**រស់នៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:៤៩:៥១**

**៤៥ទំព័រ**

ដានីៈ មុននឹងចាប់ផ្ដើមខ្ញុំចង់ស្គាល់ឈ្មោះអ៊ំពេញ ?

ស៊ីមៈៈ ខ្ញុំឈ្មោះ សុខ ស៊ីម ។

ដានីៈ សុខ?

ស៊ីមៈ សក់ ស៊ីម ។

ដានីៈ ហើយអ៊ំអាយុប៉ុន្មានហើយ?

ស៊ីមៈ ខ្ញុំមកទល់ឥឡូវនេះវាចូលជិត៧០ហើយ ៦៧ ។

ដានីៈ ៦៧ឆ្នាំ?

ស៊ីមៈ បាទ!

ដានីៈ ហើយនេះគេហៅភូមិអីដែរ?

ស៊ីមៈ នេះទួលចារ ។

ដានីៈ ក្នុងឃុំ?

ស៊ីមៈ ទំនប់ដាច់ ។

ដានីៈ ស្រុកត្រពាំងប្រាសាទ?

ស៊ីមៈ ត្រពាំងប្រាសាទ ។

ដានីៈ ហើយអ៊ំស្រីគាត់ឈ្មោះអីដែរ?

ស៊ីមៈ ឈ្មោះ ម៉ឹង រឿង ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

ស៊ីមៈ គាត់អាយុ ប្អូនខ្ញុំ២ឆ្នាំ ។

ដានីៈ អ៊ីចឹងអ៊ំ៦៧ គាត់៦៥ ។

ស៊ីមៈ បាទ!

ដានី: អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

ស៊ីម: កូនខ្ញុំតែ២ទេ ៣ទាំងកូនចិញ្ចឹម ក្មួយបង្កើតយកមកចិញ្ចឹម ប្រុស២ ស្រី១ ។

ដានី: គាត់ធំៗអស់ហើយ?

ស៊ីម: មានគ្រួសារ មានកូន មានចៅ ។

ដានី: បានរៀនសូត្រខ្ពង់ខ្ពស់ដែរ?

ស៊ីម: បានរៀនអាបងនោះ ហើយអាប្អូននេះអត់ទេគ្រាន់មើលបាន ចុះកាលនោះរវល់យើងច្បាំងជាប់តាំងពីក្មេង ។

ដានី: អីចឹង?

ស៊ីម: (សើច) ។

ដានី: អ៊ំអ្នកស្រុកកំណើតនៅណាដែរ?

ស៊ីម: ខ្ញុំកំពង់ស្ពឺនោះទេ ។

ដានី: ខាងភូមិអីដែរ?

ស៊ីម: នៅភូមិព្រៃអំពាវ ឃុំស្តុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

ដានី: ហើយអ៊ំកាលពីក្មេងៗ អ៊ំរៀនសូត្រដល់ណាដែរ?

ស៊ីម: ខ្ញុំកាលនោះមានវត្តលោក សាស្ត្រាវែងៗ រៀនហ្នឹង ។

ដានី: អ៊ំបានបួសដែរ?

ស៊ីម: អត់បានបួសទេ ដល់សម័យយើងដេញបារាំង ។

ដានី: ឆ្នាំណាទៅអ៊ំដេញបារាំង ខ្ញុំចង់ដឹងកន្លែងហ្នឹងដែរ?

ស៊ីម: ពីឆ្នាំប៉ុន្មានកាលសម្តេចឪនាំធ្វើជីវពល បង្ហាត់នារីក្លាហានដេញបារាំង ។

ដានី: ឆ្នាំ៥០?

ស៊ីម: ហុកប៉ុន្មាន ហុកសិបហើយ ។

ដានី: យើងបានឯករាជ្យពីបារាំងថ្ងៃ៩ វិច្ឆិកា ឆ្នាំ១៩៥៣ ។

ស៊ីម: ៥៣កាលហ្នឹង ខ្ញុំនៅក្មេង តែទៅធ្វើជីវពលជាមួយសម្តេចឪ ។

ដានី: កាលហ្នឹងអ៊ំរៀននៅក្នុងវត្ត សាលាវត្ត?

ស៊ីម: ក្នុងរៀន ។

ដានី: អក្សរយើងច្បាស់លាស់ដែរ?

ស៊ីម: សរសេរបាន ឥឡូវចាស់ហើយញ័រដៃ ។

ដានី: ខាងបាលីអ៊ំចេះច្រើន?

ស៊ីម: ចេះខ្លះ ។

ដានី: ហើយអ៊ំរៀបការឆ្នាំណាទៅ?

ស៊ីម: ខ្ញុំការគ្រួសារ?

ដានី: បាទ!

ស៊ីម: ខ្ញុំការតាំងពីអាយុ២៥បានមានគ្រួសារ ពីដើមទាល់តែ៣០ប្រុស ។

ដានី: អ៊ំស្រីអ្នកស្រុកកំណើតជាមួយអ៊ំដែរ?

ស៊ីម: ស្រុកជាមួយគ្នា ។

ដានី: ដល់ពេលការហើយអ៊ំប្រកបរបររកស៊ីធ្វើអីទៅ?

ស៊ីម: ការហើយធ្វើស្រែចំការ កាលសម័យនោះអត់មានធ្វើអីទេ ហើយឡើងត្នោត ។

ដានី: ធ្វើស្រែ ហើយនិងឡើងត្នោត ។

ស៊ីម: បាទ! ដល់ចូល៦៨ហ្នឹងកើតខ្មែរក្រហមក៏ចូលព្រៃរហូតទៅ ខ្ញុំអត់បាននៅស្រុកភូមិអីនឹងគេទេ ។

ដានី: ចូលព្រៃទៅអ៊ំចោលអ៊ំស្រី ឬទៅទាំងអស់គ្នា?

ស៊ីម: ហ្នឹងហើយ គេនៅភូមិស្រុក ខ្ញុំដើរព្រៃទៅ ទៅនៅរហូតរតនគិរី មណ្ឌលគិរី គ្រប់ខេត្តទាំងអស់ (សើច) ។

ដានី: បានឆ្ងាយដែរ?

ស៊ីម: បាទ!

ដានី: អ៊ំចូលកាលហ្នឹងព្រោះបើនៅសំឡូតវិញគេមានធ្វើបាតុកម្មឆ្នាំ៦៧-៦៨ហ្នឹង?

ស៊ីម: បាទ!

ដានី: អ៊ំមានដឹងរឿងហ្នឹងខ្លះទេ?

ស៊ីម: ដឹង ឆ្នាំប៉ុន្មានទេ៧០ហើយប្រុងធ្វើបាតុកម្មលួងដែលត្រង់កន្លែងខ្ញុំ ដល់ធ្វើទៅមើលឲ្យអ្នកទៅមើលផ្សារស្រង់កន្លែងស្រុកគេ សុទ្ធតែរថក្រោះ ដល់ភូមិត្រពាំងដារប្រជុំគ្នាមើលទៅមិនកើតទេ បើយើងទៅច្បាស់ជាស្លាប់ ដល់អីចឹងយប់ឡើងនាំគ្នាបើកវិទ្យុទៅប៉ះកាំងលឺសម្តេចឪ កាលហ្នឹងគេធ្វើរដ្ឋប្រហារសម្តេចឪហើយ ។

ដានី: អ៊ំកាលឆ្នាំ៦៨យើងចូលព្រៃ យើងទៅខាងណាវិញទៅ?

ស៊ីម: ហ្នឹងខាងខ្មែរក្រហម ។

ដានី: តែទៅព្រៃណាទៅ?

ស៊ីម: ព្រៃយើងនៅខាងស្រុកខ្ញុំហ្នឹង ឡើងទៅដុងតាមផ្លូវជាតិលេខ៤ ។

ដានី:		ខាងជុំវិញ?

ស៊ីម:		ហ្នឹងហើយទៅតាមហ្នឹងរហូត វាលរេញដើរតាមហ្នឹងរហូត ។

ដានី:		កាលហ្នឹងចាស់ៗដំណាលអីទៅច្រើនដែរ?

ស៊ីម:		ទៅច្រើន តែឥឡូវងាប់អស់ហើយ សុទ្ធតែមេៗ ។

ដានី:		ពីណាខ្លះទៅ?

ស៊ីម:		បងសារឿន ។

ដានី:		តាសារឿន(០៥) ។

ស៊ីម:		បងសារឿន ដែលតាម៉ុកសម្លាប់០៥ហ្នឹង ។

ដានី:		ទៅជាមួយគាត់?

ស៊ីម:		ជាមួយគ្នាទាំងអស់មួយភូមិ ។

ដានី:		ជាមួយខាងអ៊ំសឿង, តាម៉េត?

ស៊ីម:		ហ្នឹងហើយ ជាមួយគ្នា ។

ដានី:		ដល់ពេលរដ្ឋប្រហារឆ្នាំ៧០ យើងទៅណាទៅណី?

ស៊ីម:		កាល៧០ហើយ ចូលមកវៃអានល់ហ្នឹងម្តង ខ្មែរក្រហមអ្នកវៃ ។

ដានី:		កាលហ្នឹងយើងមានជាកងពលហើយនៅ?

ស៊ីម:		នៅទេ ទាល់៧២បានរៀបជាកងពលហើយ ។

ដានី:		គេរៀបកងពល កាលហ្នឹងកងពលលេខប៉ុន្មានទៅអ៊ំ?

ស៊ីម:		កងពលមើល ១៦០កើតក្រោយទេ ១៤០ កងតាបិតហ្នឹង១៦០ ហើយ១៤០កើតក្រោយបំបែកមកគេហៅភូមិភាគពិសេស ខាងបង០៥ គាត់ធ្វើមេភូមិភាគពិសេស ខ្ញុំវិញ

ដានី:		កាលហ្នឹងគេហៅកងពល១៤?

ស៊ីម:		ហ្នឹងហើយកងពល១៤ ។

ដានី:		ដែលតា០៥គាត់ធ្វើមេ?

ស៊ីម:		ធ្វើមេ ។

ដានី:		ហើយកងពល១៤មានកងទ័ពពីខាងណាខ្លះដែលចូលរួម?

ស៊ីម:		កងទ័ពកាលហ្នឹងមានប៉ែកខាងនីរតីទេ ហើយដល់នេះបានយកពីយើងប៉ែកខាងជើងទៅដែរពីកំពង់ឆ្នាំងខ្លះ បញ្ចូលគ្នាបំពេញជាកងពល ។

ដានី:		មានខាងតាសាន ទៅជាមួយ?

ស៊ីម:		ទៅជាមួយគ្នាទាំងអស់ ។

ដានី:	កាលហ្នឹងអ៊ំនៅក្នុងវរសេនាធំណាទៅ?

ស៊ីម:	ខ្ញុំដំបូងនៅវរសេនាធំ១៨ដែរ បានគេកើតកងពលដាក់កងពល១៨ បង០៥កាន់ ។

ដានី:	ដល់ពេលកងពល១៨ទៅអ៊ំនៅក្នុងជួរកងពលដែរ ឬយើងនៅខាងវរៈទេ?

ស៊ីម:	ខ្ញុំជាមួយបង០៥ ឡើងជាប់ជាមួយគ្នារហូត ។

ដានី:	នៅគណៈកងពលជាមួយគាត់ជាប់?

ស៊ីម:	ហ្នឹងហើយ ។

ដានី:	កាលហ្នឹងគណៈកងពលមានគ្នាប៉ុន្មាននាក់?

ស៊ីម:	មានតែ២នាក់ទេ ដល់យកខ្ញុំទៅឲ្យកាន់កង៨០១ទៅ គាត់បានតាសាន ដៃគូគាត់ ។ តាសាន ជាជន្ទងគាត់ បានប្រហែល១ឆ្នាំដកតាសាន មកដាក់ខាងកងពលលេខប៉ុន្មានទេនៅខាងមណ្ឌលគិរី ភ្លេចឈ្មោះហើយកងពល ។

ដានី:	កងពល៩២០ ។

ស៊ីម:	បាទ! ៩២០ ចេះភ្លេច ។

ដានី:	អ៊ំកាលពីបង្កើតដំបូងកងពល១៨ មានប៉ុន្មានវរសេនាធំទៅអ៊ំ?

ស៊ីម:	បង្កើតដំបូងវាមានដល់ទៅ៥វរសេនាធំ ។

ដានី:	កាលយើងទៅខាងកំពង់ស្ពឺ?

ស៊ីម:	ហ្នឹងហើយ ។

ដានី:	វរសេនាធំមួយៗ អ៊ុង វ៉ែម គាត់កាន់វរសេនាធំមួយដែរ?

ស៊ីម:	ហ្នឹងហើយមួយដែល ។

ដានី:	អ៊ំចាំថាពីណាខ្លះដែលជួរក្នុងវរសេនាធំ?

ស៊ីម:	វរសេនាធំកាលជំនាន់ហ្នឹងមានតែ២នាក់ទេ អត់មានច្រើនទេ ក្រៅពីហ្នឹងវរសេនាតូចៗ ហើយសមាជិកប្រជុំអីវរសេនាតូច ។

ដានី:	ពីរនាក់ អ៊ុង វ៉ែម មួយហើយពីណាទៀត?

ស៊ីម:	តាវ៉ែម ជាមួយតាប្រ៉ុ ។

ដានី:	តាវ៉ែម ហើយតាប្រ៉ុ ទេ?

ស៊ីម:	បាទ!

ដានី:	តាប្រ៉ុ ជនជាតិ ឬខ្មែរយើង?

ស៊ីម:	ជនជាតិទេ ។

ដានី:	តាប្រ៉ុ កាលហ្នឹងអ៊ំយើងនៅជាប់ជាមួយកងពលតាំងពីដើមមក ។

ស៊ីម៖ គ្រាន់តែមើលវរសេនាធំណាបែបមិនស្រួល បង០៥ឲ្យខ្ញុំទៅចូលរួមដឹកនាំជួយគេហ្នឹងទៅបានប៉ុន្មានថ្ងៃហៅមកវិញ ។

ដានី៖ អ៊ំនៅមន្ទីរកងពល?

ស៊ីម៖ បាទ! ២នាក់ ។

ដានី៖ ពេលដែលវ៉ៃបានទីក្រុងភ្នំពេញដែលខាងខ្មែរក្រហមឈ្នះហើយ កាលហ្នឹងយើងមកនៅកន្លែងណាទៅ?

ស៊ីម៖ កាលហ្នឹងគ្រាន់តែឈ្នះហើយសព្វគ្រប់អស់ យើង៧៥យើងឈ្នះខែប៉ុន្មាន?

ដានី៖ ខែ៤ ខែមេសា ។

ស៊ីម៖ ខែ៤ ដល់ខែ៨ ខ្ញុំហើយនិងបង០៥ បញ្ជូនទៅរតនគិរីរហូត ។

ដានី៖ កាលហ្នឹងអ៊ំម៉េច?

ស៊ីម៖ អត់បាននៅភ្នំពេញរហូតទេ ។

ដានី៖ កាលហ្នឹងយ៉ាងម៉េចបានកងរបស់អ៊ំត្រូវបញ្ជូនទៅរតនគិរី?

ស៊ីម៖ យួនវាអត់ហើយពីស្ទឹងត្រែង ពីអីទាំងអស់ ។

ដានី៖ ហើយកាលហ្នឹងដូចឈ្មោះកងពល ពីកង១៨ទៅកង៨០១វិញ?

ស៊ីម៖ ហ្នឹងហើយ ។

ដានី៖ ម៉េចបានគេដូរឈ្មោះអីចឹង អ៊ំដឹងទេ?

ស៊ីម៖ ៨០១កងហ្នឹងឈ្មោះពីកំណើតតែម្តង ៨០១ពីដើមគឺថាកងវរៈទេ ដល់នេះទៅវាបែកធំគេដាក់៨០១ប្រចាំនៅភូមិភាគឥសាន ។

ដានី៖ ដំបូងជាកងពល១៨?

ស៊ីម៖ ហ្នឹងហើយកងពល អត់ទេ១៨បង្កើតដល់ពេញអស់បានបង្កើតទេកងពល១៨ ដល់យើងប្រកាច់បញ្ចូលគ្នាទៅ ជ្រើសរើសយកគ្រប់អង្គភាព ។

ដានី៖ កាលមុនយើងមានកង១៨០, កង១៦០ ក្រោយមកបានគេប្រកាច់ទៅចេញកង១៨ ។ កង១៨យើងវ៉ៃឈ្នះទីក្រុងភ្នំពេញហើយ បានដូរឈ្មោះទៅ៨០១វិញ?

ស៊ីម៖ ៨០១ប្រចាំនៅភូមិភាគឥសាន ហើយ៩២០ប្រចាំខាងមណ្ឌលគិរី ។

ដានី៖ កាលហ្នឹងអ៊ំនៅកន្លែងណាទៅ? នៅរតនគិរី?

ស៊ីម៖ រតនគិរីនៅសៀមបាងហ្នឹង ។ សៀមបាងកន្លែងវរសេនាធំ ហើយកងពលនៅនេះគេរាល់ថ្ងៃ ។

ដានី៖ កងពលនៅបាងលុង ឬនៅវើនសៃ?

ស៊ីម៖ វ៉ើនសែ ។

ដានី៖ ដល់អីចឹងអ៊ំមកទទួលវរសេនាធំវិញ?

ស៊ីម៖ ហ្នឹងហើយ ។

ដានី៖ អ៊ំមកទទួលវរសេនាធំនៅសៀមបាង យើងការពារព្រំដែនដែលអត់ទេ?

ស៊ីម៖ ព្រំដែនលាវហ្នឹង ។

ដានី៖ ដំក្រឡខាងវរសេនាធំរបស់អ៊ំ?

ស៊ីម៖ ហ្នឹងហើយ ។

ដានី៖ កាលហ្នឹងយ៉ាងម៉េចដែលដូចថាអ៊ំនៅខាងកំពង់ស្ពឺ យើងទៅខាងរតនគិរី?

ស៊ីម៖ អត់អីទេ ដូចបញ្ចូលសាច់គ្នាឆាប់តែម្ដង ជនជាតិហើយនិងអង្គភាពស្រឡាញ់គ្នាយក អត់មានពិបាកទេ ដឹកនាំទៅស្រួល ។

ដានី៖ ដូចជំងឺឈឺស្កាត់អីយ៉ាងម៉េចដែរ? ព្រោះខាងហ្នឹងចាញ់ច្រើន?

ស៊ីម៖ ទៅដំបូងស្លាប់អស់ច្រើនណាស់ គ្រុនចាញ់តែម្ដង អត់ចាញ់តែមេ ហើយខ្ញុំមិនដឹងម៉េចទៅហ្នឹងគេចាញ់ គេឈឺងាប់ ខ្ញុំអត់ដែលអីទេ មិនដឹងម៉េច អត់គ្រុនចាញ់នឹងគេ ។ បង០៥តានេះពូកែណាស់អត់ចេះគ្រុនចាញ់ ។ ពូកែម៉េចបើដើរយើងនោះសព្វដីអស់ហើយ មកនេះទៀតម៉េចចាញ់ សើចលេងពេញហ្នឹង ។

ដានី៖ កាលហ្នឹងម៉េចបានគាត់ឲ្យអ៊ំមកដឹកនាំវរសេនាធំ៨១វិញ?

ស៊ីម៖ អត់ទេចេះ វរសេនាធំត្រូវយន្តហោះទម្លាក់ស្លាប់ ។

ដានី៖ ពីណាគេដែលធ្លាក់ស្លាប់ហ្នឹង?

ស៊ីម៖ ខ្មោចនេះ ទំរាំយកខ្លួន ទៅដាក់វិញ ភ្លេចឈ្មោះ វរសេនាធំហ្នឹងស្លាប់ទៅ បានខ្ញុំទៅប្រចាំការបានប្រហែលជាកន្លះខែចូលសមរភូមិ បានគាត់ប្ដូរយកខ្លួន យកទៅដាក់វិញប្ដូរពី៨១ ។

ដានី៖ ដល់ពេល៨២?

ស៊ីម៖ ៨២ហ្នឹងខ្ញុំទៅនៅហ្នឹង ដល់ពេលនេះបានផ្លាស់ទៀត យកមិត្តណាមកដាក់ទៀត ។

ដានី៖ អីចឹងតាខ្លួន គាត់នៅវរសេនាធំ៨១រហូត?

ស៊ីម៖ ៨១ដល់នេះទៅបានដកខ្លួន ពី៨១យកខ្ញុំមកវិញ មកនៅជាមួយគាត់វិញទៅ ។

ដានី៖ អីចឹងតាខ្លួន គាត់មកកាន់៨១ ដកអ៊ំមកនៅ?

ស៊ីម៖ ដកខ្លួន ពី៨១យកទៅដាក់៨២ ។

ដានី៖ ហើយយក៨១ឲ្យអ៊ំមកវិញដដែល?

ស៊ីម៖ អត់ទេ នៅកន្លែងកងពល ។

ដានី:	នៅមន្ទីរកងពលវិញ?

ស៊ីម:	ហ្នឹងហើយ ។

ដានី:	អ៊ំនៅមន្ទីរនៅជាគណៈមន្ទីរ ឬក៏ជាគណៈកងពល?

ស៊ីម:	អត់ទេ ជាខាងយោធា ។ បង០៥ គាត់នយោបាយ មានតែ២នាក់ហ្នឹង ។

ដានី:	កាលហ្នឹងតា០៥ គាត់នយោបាយ អ៊ំខាងយោធា?

ស៊ីម:	ខាងសមរភូមិ ។

ដានី:	កាលហ្នឹងអ៊ំមានលេខហៅដែរ ឬហៅឈ្មោះ?

ស៊ីម:	ហៅលេខដែរ ។

ដានី:	លេខប៉ុន្មានដែរ?

ស៊ីម:	កាលនោះលេខហុកប៉ុន្មានទេ បង០៥ដាក់ឲ្យ ហៅតែ២នាក់ទេ ក្រៅពីហ្នឹងមិនបាច់ទេ ។

ដានី:	ខាងតាឡី គាត់អត់នេះទេ?

ស៊ីម:	តាឡី គាត់កងវរសេនាធំ នៅប៉ែកខាងតាមទន្លេសេសានទៅលើ ។

ដានី:	៨៣?

ស៊ីម:	ហ្នឹងហើយ៨៣ រកនឹកមិនឃើញ ។

ដានី:	តាឡី៨៣ ហើយតាខួនគាត់៨២ ដល់ពេល៨១?

ស៊ីម:	៨១ខ្មោចនេះស្លាប់អស់ហើយ ស្លាប់កាលនៅវៃក្មានោះទេ ផ្លាស់ថ្មីទៀតមិនដឹងអ្នកណាខ្លះ ខ្ញុំបែកគ្នាទៅ ផ្លាស់ប្តូរយកទៅលិចទៅកើត កាលហ្នឹងវាប្តូរយកទៅនៅកន្លែងប៉ុល ពត ។

ដានី:	តាសារឿន មួយទៀត កែវ សារឿន?

ស៊ីម:	រឿន មួយទៀតនៅនេះ ។

ដានី:	កំពង់ស្ពឺដែរ?

ស៊ីម:	ហ្នឹងហើយកំពង់ស្ពឺដែរ ។

ដានី:	គាត់នៅខាងណាដែរ? គាត់នៅខាង?

ស៊ីម:	មួយសូ សារឿន ។

ដានី:	បាទ! មួយ សូ សារឿន ហើយមួយទៀត កែវ សារឿន ។ រឿន គាត់កាន់កងពល ឬកាន់វរៈ?

ស៊ីម:	នៅខាងយើងនេះ នៅខាងអន្លង់វែង ដល់នៅហ្នឹងបានប៉ុន្មាន ដល់ខ្លះខាងលិចយកទៅលិចទៀត ។

ដានី:	យកទៅខាង?

ស៊ីមៈ យកទៅខាងមេធំលិចនោះ សំឡូត ប៉ៃលិន ។

ដានីៈ អ៊ំដល់ពេលយើងនៅរតនគិរី កាលហ្នឹងប្រពន្ធ អ៊ំស្រី កូនទៅនៅជាមួយដែរ?

ស៊ីមៈ ដល់នេះបានគេយកទៅ ជិតនឹងចាញ់យួនហើយបានគេយកទៅ ចុង៧៧បានទៅ ។

ដានីៈ ៧៧ហើយបានទៅជួបជុំគ្នា?

ស៊ីមៈ ទៅបានម៉ារត់ ។

ដានីៈ អ៊ំកាលហ្នឹងយើងយ៉ាងម៉េចបានយើងវៃចាញ់យួន? យើងមានមូលហេតុដែរ?

ស៊ីមៈ ផ្នែកខាងនោះខ្ញុំអត់ដឹងដែរ កាលហ្នឹងខ្ញុំចូលរហូតទៅដល់ដុកកីនោះហើយ ជាមួយអាលាង នៅនេះ ។

ដានីៈ ជាមួយ លាង!

ស៊ីមៈ លាង មេទ័ព កាលហ្នឹងវាកងពិសេស ជាប់ជាមួយលាងហ្នឹងឯង រហូតដល់ដុកកីវៃជិតដាច់ ហើយ វាបេះតែប្រមុលចេញនេះ ចេញនោះ ស្រាប់តែបាន២-៣ថ្ងៃ ភ្នំពេញនេះគេ ជយោលាន់ ឯងនៅរត់កណ្ដាលស្រុកយួន ។

ដានីៈ យើងនៅខាងក្នុងហើយ?

ស៊ីមៈ ហ្នឹងហើយ ។

ដានីៈ កាលហ្នឹងតាលាង គាត់នៅវរសេនាធំណាទៅ?

ស៊ីមៈ វាខាងកងពិសេស កងពលធំហ្នឹងតែម្ដង ពូកែណាស់អានោះ ។

ដានីៈ គាត់កងពិសេសរបស់កងពលធំ ជាមួយជិនាន់តាឡូច?

ស៊ីមៈ ហ្នឹងហើយ តែតាឡូច វាខិលខូចរឿងស្រីញី ស្ដាយ ។

ដានីៈ អ៊ំកាលពីវរសេនាធំ៨១ ម៉ៅ គាត់ធ្លាប់ធ្វើប្រធាននៅហ្នឹងដែរ?

ស៊ីមៈ ហ្នឹងហើយ ម៉ៅ មិនដឹងនៅ ស្លាប់បាត់ហើយដឹងទៅលិច ។

ដានីៈ ម៉ៅ គាត់នៅខាងសំឡូត?

ស៊ីមៈ ហ្នឹងហើយទៅសំឡូត ម៉ៅ វានៅ៨១ ដកខ្លួនហ្នឹងមកនៅម៉ៅ ហ្នឹងឯង ។

ដានីៈ ដកខ្លួន មកនៅ៨២វិញ ។

ស៊ីមៈ ហ្នឹងហើយ យកខ្លួន មក៨២ ។

ដានីៈ ចុះ ស៊ុន?

ស៊ីមៈ តាស៊ុន កាលហ្នឹងគេដកយកទៅណាទេ ដកចេញពីហ្នឹង តាស៊ុន ។ ដំបូងគាត់នៅ៨២ដែរ តាស៊ុន ហ្នឹងដំបូង ដកយកមកភ្នំពេញខ្ញុំមិនដឹងកាន់ខាងអី តាស៊ុន ។

ដានី: អីចឹងអ៊ំពេលដែលចូលទៅដល់ស្រុកយួន ចូលដល់ដុកកីហ្នឹងយ៉ាងម៉េចទៅ ពេលយើងបែកភ្នំពេញ ហើយអ៊ំយ៉ាងម៉េចទៀតទៅ?

ស៊ីម: ចេញមកវិញមក ដកចេញមក វិរកអីបើអស់អីហើយ ។

ដានី: ដកចេញមកវិញមកជួបកងពលវិញដែលអត់?

ស៊ីម: មកជួបគ្នាកណ្តាលព្រៃ ។

ដានី: ជួបគ្នាកណ្តាលព្រៃ?

ស៊ីម: ជួបមណ្ឌលគិរី ។

ដានី: ចេញពីនោះមកមណ្ឌលគិរីវិញ?

ស៊ីម: សំដៅមកមណ្ឌលគិរី បើចេញទៅផ្លូវនោះម៉េចរួច បើវាបើកឡានបាញ់ម៉េចក៏មិនតដែរ គិតតែពីចូលមកយើងរកកន្លែងយើង រកបានលុង ។

ដានី: ដល់មកព្រៃយើងចាប់ផ្តើមរៀបចំយុទ្ធសាស្ត្រយ៉ាងម៉េចដើម្បីទប់ទល់ជាមួយយួន?

ស៊ីម: ចាប់ផ្តើមពិគ្រោះគ្នាបានលើបង០៥ នៅភ្នំពីកទល់ដែនលាវ ឡើងទៅលើស្រែកមកថាឥឡូវផ្ញើសង្រ្គាមឈប ។

ដានី: តែកំលាំងយើងពេលយួនចូលមកអីចឹងបែកខ្ញែកគ្នាអស់?

ស៊ីម: បែក ដល់នេះមកជុំគ្នាវិញ គេអូទាក់ទងគ្នាទៅ មកជួបកន្លែងណាៗ ។

ដានី: ចុះប្រពន្ធកូនអ៊ំ?

ស៊ីម: ប្រពន្ធកូនរត់អស់ហើយ ។

ដានី: បែកខ្ញែកគ្នា?

ស៊ីម: បាទ!

ដានី: អ៊ំស្រីបែកគ្នាអស់?

ស៊ីម: បែកពីខ្ញុំ គេតាមទាន់នៅឆ្លងទន្លេហើយ គេតាមចាប់ដាក់កោះកន្ទុយគោហ្នឹងនៅជាប់គុកកោះកន្ទុយគោ ។

ដានី: យ៉ាងម៉េចទៀតទៅយើងបែកមក៧៩ ពេលដែលយួនចូលមកយើងរៀបចំកងទ័ពឡើងវិញយ៉ាងម៉េចខ្លះទៅ?

ស៊ីម: យើងរៀបចំដាក់ជាក្រុមៗកងវរៈឈប បានដល់ឆ្នាំ៨០បានឡើងមកភ្នំដងរែក មេធំហៅឡើងមកជួបគ្នា ។

ដានី: ប៉ុន្តែយើងនៅខាងមណ្ឌលគិរីនៅខាងកើតទន្លេ?

ស៊ីម: ហ្នឹងហើយ ។

ដានីៈ យើងឆ្លងទន្លេមកយ៉ាងម៉េចទៅ បើយួនចូលពេញ?

ស៊ីមៈ ឆ្លងហែល ។

ដានីៈ អ៊ំមិនមែនអ្នកទន្លេផងហែលយ៉ាងម៉េចទៅ?

ស៊ីមៈ អត់ គេទាហានគេជួយយោងទៅ ចងធ្វើពោងស្រួលសឹងអីមានលំបាកអី ។

ដានីៈ ចងនឹងអី?

ស៊ីមៈ កៅស៊ូយើងនឹង ចងធ្វើក្បូន បើនេះវិញកាប់ឫស្សី សំបូរឫស្សីណាស់តាមមាត់ទន្លេ ។

ដានីៈ ព្រោះមានកាំភ្លើង មានទុះសៀ ។

ស៊ីមៈ ហ្នឹងហើយមានមួយចប់ ដាក់ទៅ ។

ដានីៈ ឆ្លងពីកន្លែងណាមកកន្លែងណា?

ស៊ីមៈ ប្រឡោះយើងស្រែក្រសាំង ។

ដានីៈ ស្រែក្រសាំងខាងស្ទឹងត្រែង?

ស៊ីមៈ ស្ទឹងត្រែង ។

ដានីៈ ចេញមកខាងលិចទន្លេមកចូលនៅកន្លែងណាវិញទៅ?

ស៊ីមៈ មករំដេង ភូមិរុន ឆ្លងមកឆែប ផ្លូវឆែប ។ កំលាំងតូចៗពិបាកឆ្លង ដូចខ្ញុំមានអីលំបាកអី
ទាក់ទងជាមួយកាណូតគេមក ដាក់តែមួយប្រឹបអស់ គ្នា៣០០-៤០០នាក់ ។

ដានីៈ កាណូតខាងណាគេមកជួយឆ្លង?

ស៊ីមៈ ឥឡូវមកនៅយើងដែរ ធ្វើអាចារ្យ កាលនោះវាធ្វើទាហានខេត្ត ទាក់ទងទាហានខេត្ត ។

ដានីៈ ទាក់ទងទាហានបានដែរ?

ស៊ីមៈ ទាក់ទងគ្នាបាន គេយកកាណូត៤-៥ដឹកវិលចុះវិលឡើងហើយ ។

ដានីៈ ដល់ឆ្នាំ៨០អ៊ំឡើងមកលើភ្នំ?

ស៊ីមៈ បាទ!

ដានីៈ ខាងលើហៅទៅ?

ស៊ីមៈ បាទ!

ដានីៈ អ៊ំឡើងទៅលើភ្នំដំបូងនៅណាទៅ?

ស៊ីមៈ ១០០៣ ។

ដានីៈ មួយពាន់ប៉ុន្មានទៅអ៊ំ?

ស៊ីមៈ ឡើងទៅដំបូងនៅនោះបានប៉ុន្មាន តែតាម៉ុក ហៅមកនៅកន្លែងគាត់១០០៣នេះ ។

ដានីៈ អីចឹងឡើងដំបូង ឡើងទៅខាង?

សុីមៈ ទល់ដែនលាវ ។

ដានីៈ ខាងទន្លេល្អោ?

សុីមៈ គេហៅមុំ៣ ។

ដានីៈ អ៊ំឡើងឆ្នាំ៨០ ខែប៉ុន្មានទៅឡើងមកដល់ទន្លេល្អោ?

សុីមៈ ខែ៧ ខែទឹកឡើង ទឹកជន់ ។

ដានីៈ អ៊ំឡើងទៅដំបូងគេ ឬមានក្រុមគេនៅ?

សុីមៈ មានគេនៅហ្នឹងស្រាប់ ពួកអ្នករត់មុន យើងនៅជាប់ស្រុកយួនបានអីរត់ គេអ្នករត់ ។

ដានីៈ អ៊ំកន្លែងគេដាក់ឈ្មោះថា១០០១, ១០០២, ១០០៣ អ៊ំដឹងថាម៉េចបានគេដាក់ឈ្មោះអីចឹង?

សុីមៈ ដាក់ហ្នឹងបានន័យថាទី១ គឺទន្លេល្អោ ឡើងមកដល់កន្លែងហ្នឹងដាក់១០០១ ហើយដល់មកប្រឡោះកណ្តាលនេះ ខាងនោះអានសេះ ១០០២ ដល់មកដល់កន្លែងនេះ១០០៣ ។

ដានីៈ អីចឹងពីទន្លេល្អោ យើងមកដល់ដំបូងគេ?

សុីមៈ ហ្នឹងហើយ ឡើងមកដល់ដំបូងគេតែផ្លូវហ្នឹងទេ ។

ដានីៈ ដោយសារដាក់ឈ្មោះ១ពាន់ហ្នឹងដោយសារកំពស់ភ្នំ១ពាន់ ។

កូនៈ អត់មានទេ គេដាក់ដើម្បីកន្លែងលេខ កន្លែងចំណុចគេ ជំរំតស៊ូខ្មែរក្រហម ។

សុីមៈ ស្រណុកទាក់ទងគ្នា ។

ដានីៈ អីចឹងកន្លែង១០០១ទន្លេល្អោ ពីត្រឹមណាដល់ត្រឹមណាបើតាមអ៊ំដឹង?

សុីមៈ ឆ្ងាយដែរ ប៉ុន្មានគីឡូទេ ដើរបត់ចុះបត់ឡើង ខ្នងភ្នំមានត្រង់ដូចផ្លូវយើងណា ។

ដានីៈ ដល់ពេល១០០២?

កូនៈ ឆ្ងាយពីគ្នា បើដើរដេកលើភ្នំ ដេក២យប់ ព្រោះស្ពាយរបស់ធ្ងន់ ។

សុីមៈ ហើយបើ១០០២-១០០៣នេះដេក១យប់ អានេះផ្លូវវាស្រួល ។

ដានីៈ ១០០២កន្លែងអានសេះ?

កូនៈ ខាងនោះអានសេះ ។

សុីមៈ បាទ!

ដានីៈ ខាងណាអានសេះ?

កូនៈ ខាងនោះ វាតំបន់អានសេះហ្នឹងឯង តែវាខាងនោះ ។

ដានីៈ បានន័យថាបើពីអានសេះមកព្រះវិហារ?

កូនៈ ជៀង ។

ដានី:	បើពីអានសេះមក១០០១វិញ?

កូន:	ពីអានសេះទៅខាងកើត អានសេះហ្នឹង១០០២ ។

ដានី:	ពីអានសេះទៅខាងកើត១០០២?

កូន:	បាទ! បើទៅពី១០០២ទៅខាងកើតដេកពីរយប់ដល់ទឹកដី ជាអន្តភាពគេនៅតំបន់ ១០០១ ។

ដានី:	បើ១០០៣ពីត្រឹមណា?

កូន:	១០០៣ឆ្លងប្រាសាទព្រះវិហារមកខាងនេះហ្នឹង១០០៣ ។

ដានី:	អ៊ីចឹងពី១០០៣ ចាប់ពីឆ្លងប្រាសាទព្រះវិហារ មកខាងអន្លង់វែង ខាងត្រពាំងប្រាសាទ?

កូន:	បើចំអន្លង់វែងគេហៅតំបន់៨០៨ ។

ដានី:	អ៊ីចឹងអ៊ីកន្លែងអន្លង់វែងគេហៅ៨០៨?

ស៊ឹម:	ហ្នឹងលើភ្នំ ។

កូន:	ហៅតំបន់៨០៨ ។ ៨០៨ខាងនោះអន្លង់វែងបន្តិច ។

ដានី:	អ៊ីចឹងអ៊ំឡើងមកដំបូងនៅកន្លែង១០០១បានតែប៉ុន្មានថ្ងៃទេ?

ស៊ឹម:	ហ្នឹងហើយ បានប៉ុន្មានថ្ងៃមកតាម៉ុក មកនៅជាមួយតាម៉ុក ។

កូន:	បានប៉ុន្មានខែដែរ ។

ដានី:	អ៊ីចឹងអ៊ំឈប់នៅ១០០១ មកនៅជាមួយតាម៉ុក វិញ?

ស៊ឹម:	ហ្នឹងហើយមកនៅជាមួយ តាម៉ុកវិញ ។

ដានី:	អ៊ីចឹងអ៊ំចេញពីកងពល៨០១ ឬអត់ទេ?

ស៊ឹម:	ហ្នឹងហើយចេញមកហើយ ចេញមកនៅនេះ គេចាត់តាំងជាកងអន្តរាគមន៍ ជុំវិញ សៀមរាបនេះ ។

កូន:	កងអន្តរាគមន៍៩៨០វិញ ។

ដានី:	អ៊ីចឹងអ៊ំមកនៅ៩៨០វិញ?

ស៊ឹម:	បាទ!

ដានី:	ដាក់លេខ៩៨០ហ្នឹង កើតខែ៩ ឆ្នាំ១៩៨០ ត្រូវអត់?

ស៊ឹម:	មិនដឹងម៉េចទេ ចេះតែដាក់ៗ ។

កូន:	មិនមែនចេះតែដាក់ទេ គេដាក់ដេញលេខកង ដេញតាមជើងទឹក ។

ដានី:	អ៊ីចឹងអ៊ំមកនៅ៩៨០វិញ?

សុីមៈ ហ្នឹងហើយ មកបង្កើតថ្មីតែម្តង យកមកដាក់ដាកង៩៨០អីចឹងមួយសំរាប់ពិនិត្យតាមដានជុំវិញសៀមរាបយើងហ្នឹង។

ដានីៈ គេហៅ៩៨០កងពលអន្តរាគមន៍របស់តាម៉ុក ត្រូវហើយ?

សុីមៈ ហ្នឹងហើយ។

ដានីៈ អីចឹងកាលហ្នឹងប្រធានកងពលពីណាគេ?

សុីមៈ កាលហ្នឹងដំបូងមានតាសឿន ២នាក់ហ្នឹង។

កូនៈ មានតែឪឯងនិងតាសឿន ក្រោយមកតាម៉ុក កូនគាត់នៅខាងលិចមានបញ្ហាអីខ្លះគាត់យកមកនេះ យើងរៀបកងថ្មីគាត់យកមកដាក់។

ដានីៈ អីចឹងដំបូងបំផុត៩៨០អ៊ំទេ?

កូនៈ ពីរនាក់ពូសឿន។

ដានីៈ សឿន ដែលគាត់នៅខាង។

សុីមៈ គេហៅសឿន រថក្រោះៗ។

ដានីៈ សឿន រថក្រោះ ដែលមុនឡើងលើភ្នំ គាត់នៅខាងសៀមរាប ខាងព្រះវិហារហ្នឹង?

កូនៈ នៅខាងឧត្តរមានជ័យ។

ដានីៈ ឧត្តរមានជ័យនេះ។

កូនៈ ដល់គេរៀបកងគេដកគាត់មក ហើយគាត់នេះមកពី៨០៩ មកបូកបញ្ចូលគ្នា។

ដានីៈ ពីព្រោះខ្ញុំទៅខាងអន្លង់វែងគេប្រាប់ខ្ញុំថា៩៨០ហ្នឹងកើតដំបូង តាមុត គាត់អ្នក។

កូនៈ តាមុត ក្រោយទេ។

សុីមៈ តាមុត មកក្រោយទេ។

ដានីៈ តាមុត មកក្រោយទេអីចឹង?

កូនៈ ក្រោយមកមានទំនាស់បានសឿន គាត់ដកខ្លួនចូលទៅខាងប៉ៃលិន ព្រោះគាត់ដឹងប្រវត្តិតាមុតចេះចុះ មកដល់ដាក់មានគាត់ ដល់យកតាមុត មក យកគាត់ដាក់ក្រោមតាមុត ព្រោះតាមុត កូនប្រសារ គាត់អន់ចិត្តគាត់។

ដានីៈ អីចឹងអ៊ំពេលមកដល់ដំបូង អ៊ំបង្កើត៩៨០ដំបូងអ៊ំធ្វើជាប្រធាន។

សុីមៈ ហ្នឹងហើយ។

ដានីៈ ពីរនាក់សឿន អនុគាត់?

សុីមៈ បាទ!

ដានីៈ ហើយយ៉ាងម៉េចទៀតទៅកាលហ្នឹង?

សុីមៈ ដល់សឿន លែងនៅ ។ សឿន វាលាខ្ញុំ ខ្ញុំទៅហើយ បងឯងនៅបាន ខ្ញុំនៅមិនបានទេ ព្រោះអង្គភាពហ្នឹងមិនដែលមានពីរទេ វាមានតែមួយ ។

ដានីៈ គាត់ចង់និយាយថាភ្នំមួយមិនអាចមានខ្លាពីរ?

សុីមៈ ព្រោះស្ទី មេវាមួយនៅជាមួយសឿន បានតែប៉ុន្មានថ្ងៃទេ បាត់ខ្លួនហើយ ។

ដានីៈ មេពីណាគេ?

សុីមៈ មេនៅយើងកាលនោះ វានៅដើងទឹក ។

ដានីៈ នៅ១៦៤ជាមួយតាមុត?

សុីមៈ ហ្នឹងហើយ នៅជាមួយតាមុត ។

ដានីៈ មេរបស់សឿន ហ្នឹងបាត់មួយហើយ?

សុីមៈ ពីរនាក់ហ្នឹងនៅជាមួយតាមុត ហ្នឹង ។

ដានីៈ បានន័យថាសឿន រថក្រោះ ហើយនិងតាមុត គាត់មានទំនាស់គ្នា?

សុីមៈ វាអីចឹង ។

ដានីៈ ដល់តាម៉ុក ដកតាមុត មកកាន់៩៨០ សឿន ហ្នឹងគាត់ឈប់ សុំលាចេញ?

កូនៈ គាត់ទៅនោះ ចេញទៅ កាលសម័យនោះគេទើបតែរំលាយបក្សកុំមុយនីស្តខ្មែរក្រហម បើគាត់នៅ ក៏នៅអត់សុខដែរ អីចឹងគាត់មានតែចេញទៅ ។

សុីមៈ អត់សុខទេ មានតែចេញ បើនិយាយវាលាខ្ញុំស្រួលបួលហ្នឹង បងឯងបើតាឲ្យតាម ៗ ទៅ បើខ្ញុំបាញ់ទេបងឯង ។

ដានីៈ គាត់ទៅគ្នាច្រើន ឬទៅម្នាក់គាត់?

កូនៈ មួយក្រសួងមន្ទីររបស់គាត់ ។

សុីមៈ មួយមន្ទីរវាហ្នឹង ។

ដានីៈ មួយមន្ទីរហ្នឹងប៉ុន្មានទៅ?

សុីមៈ គ្នាវាច្រើនដែរ គ្រាន់តែបេ៤០មាន២០ថ្នាយដើម ។

ដានីៈ ខែប៉ុន្មានដែលដឹបូងអ៊ឹមកកាន់៩៨០ហ្នឹង?

សុីមៈ ភ្លេចអស់ហើយ ។

កូនៈ ខ្ញុំខែ១០-១១ហ្នឹងរងារ ។

សុីមៈ ខែរងារហ្នឹងឯង នៅនោះបានតែប៉ុន្មានថ្ងៃ ។

ដានីៈ ខែ១០-១១ឆ្នាំ៨០ហ្នឹងតែម្តង?

កូនៈ ៨០ ដូចគាត់ជំរាបអូនឯងថាឡើទៅនោះបានតែប៉ុន្មានខែ គេបញ្ជូនមកហ្នឹង កាលនោះខែ ៧ ប្រហែលខែ១០-១១។

ស៊ីមៈ ប៉ុន្មានខែអី ឡើងបានតិច។

ដានីៈ កាលនោះមានប៉ុន្មានវរសេនាធំទៅកាលហ្នឹង? កាលបង្កើតដំបូង?

កូនៈ ៩៨០ មាន៩១-៩២-៩៣ហ្នឹងឯង, ៩៤ខាងនារីដឹកជញ្ជូន ហ្នឹងលេខវរសេនាធំរបស់គេ។

ស៊ីមៈ នេះហើយខ្ញុំថាកូនខ្ញុំអាបងហ្នឹង។

ដានីៈ កាលហ្នឹងដល់ពេលបានប៉ុន្មានខែ? ដូចអ៊ំមានប្រសាសន៍មិញថាខែរងារឆ្នាំ៨០ អ៊ំមកបានប៉ុន្មានខែបានតាម៉ុក គាត់ហៅតាមុត មក?

ស៊ីមៈ ហ៎! បាន១ឆ្នាំហើយ បានតាមុត វាមានរឿងគេនោះនៅអត់បាន។

ដានីៈ នៅណា?

ស៊ីមៈ នៅសំឡូត កោះកុង មានរឿង។

កូនៈ មានរឿងដូចគាត់និយាយសឿន នៅអត់បេះត្រូវគេ នៅចង់តែជាន់ពន្លិចគេអត់ឲ្យមាន។

ស៊ីមៈ ទាហាន មេទាហានគេឡើងពីក្រោមមក ហើយមកហ្នឹងមាន់របស់គ្នាសោះ ប្រពន្ធហ្នឹងមិនដឹងបានអី ក៏វៃមាន់ឲ្យប្ដីហូប មកម៉ាកងគ្នាមិនមែនតិចណា៎ ក៏អីចឹងទៅចោទប្រកាន់ថាទៅលួចមាន់ ចាប់គេយកទៅបាញ់ចោល ហើយមេរបស់ខ្លួន បំរើខ្លួនហ្នឹង។

ដានីៈ បានន័យថាគាត់ជាមេបញ្ជាការមួយក្នុងកងទ័ព១៦៤ជាមួយតាមុតហ្នឹងដែរ?

ស៊ីមៈ ហ្នឹងហើយ។

ដានីៈ ហើយមេហ្នឹងត្រូវជាបងរបស់តាសឿន បងបង្កើតឬយ៉ាងម៉េច?

ស៊ីមៈ មិនដឹងម៉េចទេ។

កូនៈ មិនមែនទេ គ្រាន់តែនៅជាមួយ បងគ្រាន់តែបងនៅជាមួយគាត់ធ្វើពីលើ មិនមែនបងតាសឿន បង្កើតទេ។

ដានីៈ គាត់ចង់និយាយថា។

ស៊ីមៈ អាហ្នឹងធ្លាប់នៅទុកចិត្តគ្នា រួមអាវុធជួយគ្នាទៅវិញទៅមក ដល់គេសម្លាប់ចោលយើងខូចចិត្ត

ដានីៈ ៩៨០ហ្នឹងកាលមុនមានតាបាវ គាត់នៅក្នុងហ្នឹងដែរ?

ស៊ីមៈ នៅក្នុងហ្នឹងដែរ។

ដានីៈ កាលហ្នឹងតាបាវ គាត់នៅតាំងពីជំនាន់អ៊ំ?

ស៊ីមៈ ជំនាន់គ្នាដំបូង។

កូនៈ ជំនាន់ហ្នឹងតាបាវ គាត់ទទួលខាងដឹកជញ្ជូន ។

ស៊ីមៈ ខាងនារី ។

កូនៈ យើងហៅខាងភស្តុភា ខាងកងដឹកជញ្ជូន ។

ដានីៈ ដល់ពេលតាមុតគាត់មក តាសឿន គាត់ទៅ ។ កងពលហ្នឹងរៀបយ៉ាងម៉េចវិញទៅ?

ស៊ីមៈ នៅ២នាក់ខ្ញុំ ។

កូនៈ នៅពីរនាក់អត់ត្រូវគ្នាណា៎ ដកឲ្យមកនៅដាក់ទណ្ឌកម្មបិទចំរូងដើងភ្នំ ហ្នឹងបានខ្ញុំទៅ១០០១

ស៊ីមៈ ខ្ញុំចេះតែធ្វើ ខ្ញុំអត់មាត់អត់ករទេ គេឲ្យធ្វើអីធ្វើហ្នឹង ។

ដានីៈ ដល់ពេលតាមុត មក តាមុត ធ្វើប្រធានវិញ?

ស៊ីមៈ តាមុត ហ្នឹងគេធ្វើទៅ ។

ដានីៈ តាមុត ធ្វើប្រធានដកអី?

កូនៈ គាត់មកគាត់ប្រណែនរឿងកងទ័ពហៅគាត់នេះឪទាំងអស់ ក្នុងអង្គភាព ក្នុងកងពលហ្នឹងហៅឪៗ តាមុត របៀបគាត់មោទនភាពខ្លួនគាត់ តានេះស្អីគេអ្នកណាក៏ឪៗ ចង់ថាគាត់សំបើមម៉្លេះ ។

ដានីៈ អីចឹងបងត្រូវកូនអ៊ំបង្កើត ។

កូនៈ បាទ!

ដានីៈ បងឈ្មោះអីដែរ?

កូនៈ ខ្ញុំឈ្មោះ សក់ ដល ។

ដានីៈ កាលហ្នឹងបងនៅជាប់ជាមួយគាត់?

កូនៈ ជាប់ ។

ស៊ីមៈ ជាប់ជាមួយ ។

ដានីៈ អីចឹងគ្រាន់តែតាមុត មកដល់ភ្លាម មានរឿងជាមួយអ៊ំភ្លាម?

ស៊ីមៈ មានរហូត ។

ដានីៈ ប្រណែនអ៊ំភ្លាម?

កូនៈ គេមិនមែនធ្វើភ្លាមៗទេ គេចេះតែបង្ករមូលហេតុចេះចុះៗ ដើម្បីដកគាត់ឲ្យនៅក្រោយ ឲ្យដាច់ពីកងទ័ព ។

ស៊ីមៈ ខ្ញុំអត់ត ។

ដានីៈ ដល់អីចឹងតាមុត មកបានរយៈពេលប៉ុន្មានដែលដកអ៊ំឲ្យនៅខាងក្រោយ?

ស៊ីមៈ នៅបានយូរដែរ ។

កូនៈ ៨៣បានឪឯងទៅ២ឆ្នាំ តែគេធ្វើតាំងពី៨១ គេដកឈប់ជាប់ជាមួយកងទ័ព។

ស៊ីមៈ វាលំតែគេស្កាត់ផ្លូវ ទាហានវាទាំទៅគ្រូដើមវិញ យល់ទេគ្រូដើម។

ដានីៈ បាទ! ត្រឡប់ទៅ១០០១។

ស៊ីមៈ ហ្នឹងហើយ។

ដានីៈ អ៊ីចឹងឆ្នាំ៨៣អ៊ំត្រឡប់ទៅវិញ?

កូនៈ ៨៣ហ្នឹងក៏ខែ៧អីហ្នឹង ខែរដូវ ខែភ្ជុំ ទៅហែលទឹក។

ដានីៈ ឆ្នាំ៨៣ត្រឡប់ទៅ១០០១ យ៉ាងម៉េចតាម៉ុក គាត់ឲ្យ ដល់ពេលយើងនៅ១០០៣ ហើយ យើងទៅ១០០១វិញ គាត់អត់ថាអីទេ?

កូនៈ ទៅ១០០១ មានសុន សេន។

ស៊ីមៈ ទៅនោះអ៊ំសុន សេន។

ដានីៈ តែយើងចេញពីនេះទៅ អ៊ំមានសុំពីតាម៉ុក ទៅអត់?

ស៊ីមៈ អត់សុំទេ បើគេស្កាត់ផ្លូវហើយ។

កូនៈ យើងប្រើពាក្យថារត់ចេញតែម្តង យើងនៅលែងបាន គេគាបសង្កត់ គេចោទថាយើងខ្មាំង ចេះ ខ្មាំងចុះ យើងរស់នៅលំបាក ឲ្យតែអ្នកណាមកទាក់ទង មកលេង ចុះកងទ័ពហៅឪ ទាំងអស់ ឡើងពីធ្វើការខាងក្នុងមានអីមកផ្ញើរ មកលេង ដឹងដល់គាត់ថាប៉ុព័ន្ធ។

ដានីៈ តាមុត ឬតាម៉ុក?

ស៊ីមៈ តាមុតទេ តាម៉ុក អត់ដឹងអីទេ។

កូនៈ តាម៉ុក អត់ទេ គាត់ធ្វើហ្នឹងកុំឲ្យឆើបរួចជាន់។

ដានីៈ ដល់ពេល៨៣អ៊ំត្រឡប់ទៅវិញ?

ស៊ីមៈ ហ្នឹងហើយ។

ដានីៈ កាលជិតទាន់ហ្នឹង តាមុត អត់មានត្រឡប់ទៅខាងកោះកុងវិញទេ?

ស៊ីមៈ អត់។

កូនៈ អត់មានត្រឡប់ ទៅកោះកុងដល់ក្រោយឡើងនេះ ដូចថាខាងរដ្ឋកម្ពុជាវ៉ៃយកភ្នំ តំបន់ជំរំ ភ្នំទាំងអស់។

ដានីៈ ៨៥អីហើយ?

កូនៈ ៨៥-៨៦ហើយ។

ស៊ីមៈ ហ្នឹងហើយ។

ដានីៈ អ៊ីចឹងអ៊ំពេលហ្នឹងយើងត្រឡប់ទៅវិញ ដូចថាយើងភៀសខ្លួនទៅវិញតែម្តង ពី៨៣?

កូនៈ ភៀសខ្លួនទៅវិញដើម្បីទៅរកមិត្តភក្តិចាស់ ដើម្បីគ្រាន់តែមួយរស់ មិនមែនថាទៅរកអំណាចទេ ។

ស៊ឹមៈ អត់ទេ ។

ដានីៈ កាលហ្នឹងទៅមួយក្រុមគ្រួសារអ៊ំ?

កូនៈ ទៅមួយអង្គភាពមនុស្សប្រហែលសែសិបប៉ុន្មាននាក់ ។

ស៊ឹមៈ សែសិបប៉ុន្មាននាក់ ។

ដានីៈ កាលអ៊ំមក១០០១អ៊ំយកកំលាំងមកប៉ុន្មាន? មកនៅ១០០៣?

ស៊ឹមៈ មក១កងវរៈ គ្នា៣០០ជាង ។

ដានីៈ មួយវរសេនាតូច?

ស៊ឹមៈ ហ្នឹងហើយ ។

ដានីៈ ដល់ពេលអ៊ំត្រឡប់ទៅវិញឆ្នាំ៨៣ គ្នាតែសែសិបនាក់ទេ?

ស៊ឹមៈ ៤៧នាក់

កូនៈ គ្នានៅខាងមុខៗគ្នាអត់ដឹង គេផ្តាច់រយៈអស់ដូចខ្ញុំជំរាប ។

ដានីៈ ដល់អ្នក៤០នាក់ហ្នឹង ដូចថាគេដកឲ្យមកនៅខាងក្រោយជាមួយអ៊ំដែរ?

ស៊ឹមៈ ហ្នឹងហើយ ជាប់នឹងអង្គភាព ។

ដានីៈ ដល់ពេលអ៊ំទៅដល់វិញយ៉ាងម៉េចទៀតទៅ អ៊ំចូលក្នុង?

ស៊ឹមៈ ទៅដល់វិញទៅ អ៊ំៗហៅទៅសំរាកជាមួយ និយាយថាឥឡូវធ្វើវិញទៅ ខ្ញុំថាដូចជារាងហើយលែងធ្វើហើយ ។

កូនៈ គាត់សំរាកតាំងពីទៅពីនេះ ឲ្យធ្វើម៉េចក៏គាត់សំរាក ។

ស៊ឹមៈ ឈប់ធ្វើហើយ ធ្វើមេម៉េចវិញក៏ខ្ញុំមិនធ្វើដែរ ឲ្យគេដឹកនាំទៅក្មេងៗខ្ញុំចាស់ ដឹកនាំមកវាល្អយូរហើយ ដល់មកអាក្រក់ៗអត់ដឹងខ្លួន ខ្ចឹមណាស់ ឈប់ហើយ ។ ហើយខ្ញុំទៅណាក៏ខ្ញុំអត់ទៅដែរ លុះគ្រាតែចប់ៗទាំងអស់គ្នាហ្នឹង បើថារត់ចោលមិនរត់ចោលទេ ។

ដានីៈ អ៊ំដល់ពេលយើងទៅដល់ហ្នឹង អ៊ំៗគាត់ចង់ឲ្យអ៊ំធ្វើវិញ អ៊ំសុន សេន?

ស៊ឹមៈ ហ្នឹងហើយអ៊ំសុន សេន ។

ដានីៈ ដូចថាតា០៥, ០៦ គាត់នៅក្នុងហ្នឹងដែរ?

កូនៈ នៅខាងនោះដែរ គាត់ទទួលស្គាល់ ។

ស៊ឹមៈ នៅ ទៅនិយាយគ្នាទាំងអស់ហ្នឹង ខ្ញុំថាអត់ទេ លែងហើយ ។

ដានីៈ ដល់ពេលឈប់ទៅអ៊ំនៅណាវិញទៅអីចឹង?

កូនៈ នៅដើរមូលដ្ឋានធម្មតា ។

ស៊ីមៈ នៅហ្នឹង ។

ដានីៈ នៅមើលប្រជាជនអន្តភាព ។

កូនៈ អត់ទេ គាត់អត់ធ្វើតែម្តង គាត់អត់មើល មានគេក្មេងៗជាងគាត់គេនៅទទួលខុសត្រូវ គាត់នៅធម្មតា ។

ស៊ីមៈ អត់ធ្វើ ។

ដានីៈ ដល់ពេលអីចឹងអ៊ំៗគាត់អត់ថាអីទេ?

ស៊ីមៈ អត់ថាអី ។

ដានីៈ ដល់ឆ្នាំណាបានចេញពីកន្លែងមុំមក ពីហ្នឹងមកទៀត?

កូនៈ ពេលនេះគេបញ្ជូនដូចថា គេវ៉ៃយកជំរំលើភ្នំអស់ ទៅនៅដីថៃ គេបញ្ជូនគ្រួសារកងទ័ព ហើយគាត់នៅក្នុងវង់ហ្នឹងដែរមកជាមួយគេ មកមុំដើងអូរត្រាវ ។

ដានីៈ អីចឹងដល់ពេលយើងចេញពីមុំ៣ យើងចូលដីថៃ ហើយយើងចាក់មកនៅអូរត្រាវវិញ?

ស៊ីមៈ គេដឹកជញ្ជូនមកហ្នឹង ។

ដានីៈ ហ្នឹងខ្ញុំចង់ដឹងមួយសារទៀតដែរ កាលហ្នឹងយើងបែងចែក១០០១, ១០០២, ១០០៣ អីចឹងកំលាំងវានៅដាច់ៗពីគ្នា ដល់ពេលខាងយួនវាវ៉ៃបាននៅតាមព្រំដែនហ្នឹង អីចឹងកំលាំងយើងមកនៅខាងអូរត្រាវ យើងនៅជាមុំៗដែលយើងអតីត១០០១, ១០០២, ១០០៣ ដដែលឬយ៉ាំងម៉េច?

ស៊ីមៈ នៅតាម ។

កូនៈ ហ្នឹងហើយ ។

ដានីៈ អត់នៅចូលគ្នាទេ?

ស៊ីមៈ អត់ចូលទេ អន្តភាពណាអន្តភាពហ្នឹង ។

កូនៈ តែមិត្តភក្តិយើងដើរចេញចូលបាន ។

ដានីៈ អ៊ំសុន សេន គាត់មកហ្នឹង គាត់មកគ្រប់គ្រងហ្នឹងវិញឬអត់ទេ?

ស៊ីមៈ អត់ទេ ។

កូនៈ គាត់គ្រប់គ្រងខាងនោះ គេបែក ដូចថានៅជំរំជិត នៅហែរគ្នា ទៅត្រពាំងប្រាសាទភូមិតៗ នៅក្នុងដីថៃមានជំរំគេហៅក-៧ ។

ដានីៈ ហើយអ៊ំមកដល់កន្លែងហ្នឹងគេហៅអូរត្រាវ?

កូនៈ បាទ!

ដានី:	អ៊ំនៅតែប្រជាជនដដែល?

កូនៈ	គាត់សំរាកហើយគេឲ្យធ្វើអីក៏គាត់អត់ធ្វើ ។

ស៊ីមៈ	ហ្នឹង! ប្រកែកយករួចខ្លួន ។

ដានី:	ដូចថាក្រុមគ្រួសារបង អ៊ំស្រី បងប្អូននៅជុំគ្នាទាំងអស់ ឬអត់ទេ?

កូនៈ	នៅជុំគ្នាជាមួយប្រពន្ធកងទ័ពគេហ្នឹងដែរ ។

ដានី:	ហ្នឹងនៅក្នុងកងពលណាវិញ?

កូនៈ	កាលហ្នឹងនៅមូលក្នុងកងពល៨០១ បកទៅហ្នឹងវិញ ក្នុងវរសេនាធំគ្រួសារ០៩វិញ ។

ស៊ីមៈ	កងដើមវិញ ទៅជារឿងមួយហើយ រឿងខ្ញុំទៅជាសាច់រឿងមួយ បើតែងជារឿងវិញមិនបាច់ទេ ។

ដានី:	បើតាមបងចាំកន្លែងអូរគ្រាវហ្នឹងបើស្រុកថៃគេហៅស្អីគេ? ក្នុងស្រុកស្អីគេ?

កូនៈ	ម្តុំហ្នឹងខុនហាន និងខុនខាន ។

ដានី:	បាទ?

កូនៈ	ខុនហាន និងផ្សារខុនខាន ។

ដានី:	ស្រុកខុនហាន ផ្សារខុនខាន? អូរគ្រាវហ្នឹង?

កូនៈ	បាទ! ទៅលេង ហើយទៅទិញអីនៅហ្នឹង ។

ដានី:	ម្តុំៗគេហៅឈ្មោះអីខ្លះទៅឈ្មោះកន្លែងអូរគ្រាវ?

កូនៈ	អូរគ្រាវហ្នឹងថៃមិនដឹងហៅអី ដល់ខ្មែរយើងឃើញអូរហើយសុទ្ធតែគ្រាវ ទៅនៅចេះតែហៅខ្មែរទៅនៅ ។

ដានី:	អីចឹងទេ? ដោយសារឃើញដើមគ្រាវច្រើនហើយមានអូរហ្នឹងគេហៅអូរគ្រាវ?

កូនៈ	សុទ្ធតែគ្រាវ អូរនៅស្រុកថៃសុទ្ធតែគ្រាវ ដល់ហើយនាំគ្នានៅហ្នឹងហៅថាអូរគ្រាវ គំនិតមួយថាមានអាហ្នឹងជាភស្តុតាង ។

ដានី:	ដូចថាមានស្អីងអី?

កូនៈ	ហ្នឹងនៅហួសស្អីងចាន់ហើយ ហ្នឹងអូរគ្រាវ ។

ដានី:	អីចឹងយើងទៅអូរគ្រាវដំបូង ឬនៅកន្លែងផ្សេង?

កូនៈ	នៅកន្លែងមាត់ស្អីងចាន់ ដល់ពេលយើងនៅអីចឹងទៅប៉ះពាល់ដីចំការប្រជាជនថៃគេដូរទៅអូរគ្រាវគេហៅចងក ។

ដានី:	កន្លែងហ្នឹងគេហៅចងកទៀត ម៉េចបានគេហៅចងកអីចឹង?

កូនៈ	អត់ដឹង បែបមានអ្នកចងក ខាងហ្នឹងគេហៅច្រើនមានអ្នកអីចឹងហៅតាមហ្នឹង ។

ស៊ីមៈ ចង់កហ្នឹងលីពីប្រជាជនថៃប្រាប់វិញទេ ចង់កៗ បែបប្រជាជនគេចង់កច្រើនគ្នា ដាក់ឈ្មោះអីចឹងទៅ ។

ដានីៈ ហើយអ៊ំដូចថាយើងនៅហ្នឹងមានផ្លាស់ប្តូរទៅណាទៀត ឬនៅហ្នឹងរហូត?

កូនៈ នៅអូរគ្រាវហ្នឹង?

ដានីៈ បាទ!

កូនៈ មិនដឹងឆ្នាំប៉ុន្មានទេគេផ្លាស់ប្តូរមកខាងជាំស្វា ចំសំរោងជាតិ ។

ដានីៈ ដល់ក្រោយមកគេផ្លាស់ពីអូរគ្រាវមកនៅកន្លែងជាំស្វាវិញ?

កូនៈ បាទ!

ដានីៈ នៅអូរគ្រាវបានរយៈពេលប៉ុន្មានទៅ?

កូនៈ បាន១ឆ្នាំ ឬក៏ពីរទេ ភ្លេចដែរ ។

ដានីៈ មកនៅកន្លែងជាំស្វាហ្នឹងនៅស្រុកខុនហានដដែល ឬអត់ទេនៅស្រុកផ្សេង?

កូនៈ មិនដឹងស្រុកអីគេហ្នឹងគូស៊ីន ។

ដានីៈ ស្រុកអីគេ?

កូនៈ ខុនហាន ហើយគូស៊ីនជាប់គ្នា ។

ដានីៈ ដល់ពេលមកនៅជាំស្វាដីថៃដែរ?

កូនៈ ដីថៃ ។

ដានីៈ ម៉េចបានគេផ្លាស់ពីអូរគ្រាវហ្នឹងមកជាំស្វាវិញ?

ស៊ីមៈ ចែកគ្នានៅ នៅមួយកន្លែងវាច្រើនពេក ។

កូនៈ អូរគ្រាវ ដូចខ្ញុំនៅតាមគ្រួសារកងទ័ពរហូត ដល់អូរគ្រាវគេដាក់តែប្រជាជនសុទ្ធតែម្តង អត់មានកងទ័ព ។

ដានីៈ នៅអូរគ្រាវគេទុកតែប្រជាជនទេ?

កូនៈ បាទ!

ដានីៈ ដល់យើងមកជាំស្វាមានគ្រួសារកងទ័ព?

កូនៈ បាទ!

ដានីៈ ក្រែងអ៊ំដាច់ពីកងទ័ពហើយ?

កូនៈ អត់ទេ គាត់សំរាកអត់ធ្វើអីតែនៅក្នុងហ្នឹងដដែល ។

ស៊ីមៈ អត់ទេ នៅកងទ័ព អន្តរាគមន៍ដដែល ។

ដានីៈ សំរាកអត់ធ្វើអី?

កូនៈ អត់ធ្វើអី អត់មានកាន់ដំណែងអី ។

ដានីៈ អីចឹងមកនៅដាំស្វាហ្នឹងនៅបានយូរទេ?

កូនៈ នៅបានដល់ឆ្នាំ៩០ ចុះមក ។

ស៊ីមៈ កៅអី ៨៩ចុះមក ។

ដានីៈ ៨៩ យើងចុះមកម៉ង?

ស៊ីមៈ ចុះមកហ្នឹង កាប់ចំការ ។

ដានីៈ ចុះមកដល់នៅកន្លែងផ្ទះហ្នឹង?

ស៊ីមៈ ហ្នឹងហើយ តែនៅតាមមាត់អូរ ជួរក្រោម ។

ដានីៈ អ៊ំអាចមានប្រសាសន៍បន្តិចថា ម៉េចបាន៨៩ យើងចុះមកនៅហ្នឹង? កាលមុនហ្នឹងយើងមិនចុះមកយើងចុះមក៨៩?

ស៊ីមៈ ដល់សភាពការណ៍យួនវាធូរស្រាលមកហើយ យើងវាវ៉ៃចាញ់រឿងត្រៀមតាមដើងភ្នំហ្នឹង ផាប់ពុលវាអស់តិចណាស់ ប្រជាជនយកមកយាមក-៥ វាចាញ់ក-៥ហ្នឹងបានវាដកអស់ បានយើងចុះមកនៅហ្នឹង ។

ដានីៈ កាលហ្នឹងយើងមានផ្លូវ មានចុះមកដែលអត់?

ស៊ីមៈ អត់មានទេ ចុះមកឆ្ការព្រៃចុះមក តាមនេះជប់រុន ។

កូនៈ អត់ទាន់មានទេ ចុះផ្លូវដើរ ។

ដានីៈ តាម៉ុក ពេលដែលយើងចុះមក តាម៉ុក គាត់ឈូសផ្លូវចុះច្រកជាំមកអន្លង់វែង?

ស៊ីមៈ ឈូសតាមក្រោយ ។

ដានីៈ ផ្សេងៗគាត់មានឈូសផ្លូវចុះមកដែលអត់?

កូនៈ អត់ទាន់ឈូស ផ្លូវហ្នឹងផ្លូវចាស់កាលជំនាន់គេអត់ទាន់វ៉ៃតាមព្រំដែន នៅកន្លែង១០០៣គេធ្វើផ្លូវឡើងចុះមកតាមហ្នឹង ។

ដានីៈ តាម៉ុក អ្នកធ្វើដែរ?

កូនៈ បាទ! តាម៉ុក ។ តាម៉ុក ដាច់ដើងឈូសផ្លូវនេះឯង ព្រះប្រឡាយ ។

ដានីៈ ច្រកព្រះប្រឡាយ?

កូនៈ បាទ!

ដានីៈ បងដឹងដែលកាលហ្នឹង?

កូនៈ ខ្ញុំនៅនេះ តែដកគាត់ឲ្យបិទចំរូង ។

ដានី៖ តែហេតុការណ៍ដែលគាត់ ពេលផ្ទុះ?

កូន៖ គាត់ឈរមើលគេឈូសទេ ខ្ញុំនេះឆ្ងាយដែរ ឈរបញ្ហាគេឲ្យឈូស។

ដានី៖ ហើយកន្លែងនេះខ្ញុំឆ្ងល់បន្តិច ដំបូងតាម៉ុក គាត់គ្រប់គ្រងតែ១០០៣ទេ អ៊ំសុន សេន គាត់គ្រប់គ្រង១០០១ ដល់ពេលក្រោយមកដូចតាម៉ុក គាត់គ្រប់គ្រងទាំងអស់។

កូន៖ គ្រប់គ្រងទាំងអស់ត្រឹមនេះ។

ស៊ីម៖ ហ្នឹងហើយគ្រប់គ្រងទាំងអស់។

ដានី៖ អ៊ំសុន សេន យ៉ាងម៉េចបានឈប់គ្រប់គ្រង?

កូន៖ ដកទៅលិច ហើយគាត់ឡើងទៅ ហើយទាហានរដ្ឋាភិបាល។

ស៊ីម៖ ឡើងទៅ ហើយអ៊ំខាងលើឲ្យមកជួយតាម៉ុក គាត់ដាច់ជើងផង ហើយចាស់ ឲ្យអ៊ំសុន សេន មកជួយដឹកនាំ។

ដានី៖ មកវិញ?

ស៊ីម៖ ហ្នឹងហើយ ដល់អ៊ីចឹងហើយមកនៅវាអត់ចុះគ្នា បានឲ្យគេធ្វើឃាតគាត់ទៅ។ តាម៉ុក ហ្នឹងតែម្តង មិនមែនគេចោទមកពីបង០៥ទេ អត់ទេ ០៥នៅជាមួយខ្ញុំនេះ ស្រាប់ព្រលឹមឡើងគាត់ អ៊ឺ! លឺថាល្ងាចមិញម៉េច អ៊ំសុន សេន មានគេវៃស្លាប់អស់ហើយ ទៅមើល។

ដានី៖ តា០៥ គាត់និយាយ?

ស៊ីម៖ ហ្នឹងហើយ។

ដានី៖ អ៊ីចឹងថ្ងៃកើតហេតុអ៊ំ០៥ នៅជាមួយអ៊ំទេ?

ស៊ីម៖ ហ្នឹងហើយ នៅនឹងអូរស្វាយនេះ កន្លែងផ្ទះគាត់។

ដានី៖ ព្រោះកន្លែងហ្នឹងវាមានរឿង។

ស៊ីម៖ រឿងបញ្ហាដែលខ្លាចអ៊ំសុន សេន មកត្រួតលើគាត់ យល់ទេ។

ដានី៖ កន្លែងនេះខ្ញុំចង់បកទៅក្រោយតិច ទាក់ទងពីដំបូងឡើយដាច់ៗពីគ្នា មាន១០០១, ១០០២, ១០០៣ បើតាមខ្ញុំជួបអ៊ំ ពូ មីងច្រើនមក ដូចតាម៉ុក គាត់គ្រប់គ្រងពី ១០០៣-១០០២ ដល់ពេលអ៊ំសុន សេន គាត់១០០១ដាច់ៗ ដល់ពេលយួនវៃបាន តាមព្រំដែនហ្នឹង ពេលទៅដីថៃ អ៊ំសុន សេន គាត់មកហ្នឹងដែលអត់ទេ? ពេលយើងមក អូរត្រាវ មកជាំស្វា?

ស៊ីម៖ អត់ទេ។

កូនៈ គេខាងគាត់នៅគ្រប់គ្រងគាត់ដដែល គ្រាន់តែទៅនៅហ្នឹងក្រោមការដឹកនាំរបស់ សុន សេន គាត់គ្រប់គ្រង ចែករបប ព្រោះហូបចុកខុសគ្នាដែរ គេបើកចេញពីសុន សេន នៅអូរត្រាវ ជាប់គ្នាអីចឹង តែគេបើកចេញពីសុន សេននោះទេ តែខ្ញុំបើកផ្សេង ។

ដានីៈ ឆ្នាំណាដែលតាម៉ុក គាត់គ្រប់គ្រងទាំងអស់តែម្តង?

កូនៈ គេដកសុន សេន ទៅលិច នៅលើតាម៉ុក ទាំងអស់ ។

ដានីៈ គេដកឆ្នាំណាអ៊ំចាំទេ?

ស៊ីមៈ ភ្លេចអស់ លែងគិតគូរអីទាំងអស់ ខ្ញុំតែឈប់លែងគិតអីទាំងអស់ ។

ដានីៈ ព្រោះយើងចុះមកនៅឆ្នាំ៨៩ ។ អ៊ំសុន សេន គេដកទៅលិចមុនចុះ ឬយ៉ាំងម៉េច?

កូនៈ ទៅ គ្រាន់តែចុះមកនៅហើយ ខ្លះមកដល់អន្លង់វែងហើយគេដក មានកំលាំងខ្លះជាប់ក្រសួង មន្ទីរជាមួយសុន សេន ខាងពេទ្យ គេទៅតាមគាត់ ចុះមកដល់នៅអន្លង់វែងខ្លះហើយ ។

ដានីៈ អីចឹងពេលដែលចុះមកនៅអន្លង់វែងខ្លះក្នុងឆ្នាំ៨៩ គេដកអ៊ំសុន សេន ទៅ?

កូនៈ ពេលដែលគេផ្លាស់គាត់ មិនមែនឆ្នាំ៨៩ទេ ចូលឆ្នាំ៩០-៩១ដែលហើយ គាត់មកលេង ។

ដានីៈ ៩០-៩១?

កូនៈ បាទ! ដែលចុះ៨៩ដូចគាត់ថា ចុះមកចាប់ផ្តើមកាប់ដីនៅ មិនមែនមានផ្លូវឡានមក ។

ដានីៈ តែតាម៉ុក ដាច់ជើងឆ្នាំណាទៅ?

កូនៈ មិនដឹងឆ្នាំប៉ុន្មាន ។

ដានីៈ ក្រែងគាត់ដាច់មុនហ្នឹង?

កូនៈ មុនហ្នឹង ដែលឈូសផ្លូវ ។

ស៊ីមៈ យើងចុះមកនៅហើយបានដាច់ ឈូសផ្លូវដែលធ្វើ ។

កូនៈ ដាច់ជើងមិនទាន់មានយួនវ៉ៃយកភ្នំទេ ដាច់ជើង ។

ដានីៈ តាំងពីមុនហ្នឹងទៀត?

កូនៈ មុនហ្នឹង តាំងយើងឈូសផ្លូវខ្ញុំថា ។

ស៊ីមៈ មុនហ្នឹង ។

ដានីៈ តាំងពីមុនអ៊ំត្រឡប់មកនៅអូរត្រាវនេះ គាត់ដាច់ជើងមុនហ្នឹងទៀត?

កូនៈ បាទ! មុនហ្នឹង ។

ដានីៈ ដែលលឺថាគាត់ដាច់ជើងហ្នឹង បងនៅនោះទេ?

កូនៈ នៅនេះ ។

ដានីៈ នៅណា?

កូនៈ	នៅគេដកឲ្យនៅក្រោម ។

ដានីៈ	ឆ្នាំប៉ែត?

កូនៈ	៨៣ គាត់ដាច់ជើង ។

ដានីៈ	អ៎! កាលជំនាន់អ៊ំនៅ៩៨០?

កូនៈ	៩៨០ គេដកគាត់ចេញហើយ ដែលខ្ញុំថាគេផ្តាច់គាត់ពីកងទ័ព ។

ដានីៈ	តាម៉ុក គាត់ដាច់ជើងជំណាល៨៣?

កូនៈ	ហ្នឹងហើយក្នុងអំឡុងឆ្នាំហ្នឹង ។

ដានីៈ	កាលហ្នឹងតាម៉ុក គាត់អ្នកគ្រប់គ្រងទេនៅខាងព្រះប្រឡាយ?

កូនៈ	បាទ! គាត់គ្រប់គ្រង ក្រោមរបស់តាម៉ុក ។

ដានីៈ	ដល់ពេលតាសុន សេន ដកទៅលិចហ្នឹងខ្ទង់ឆ្នាំកៅ?

កូនៈ	ហ្នឹងនេះហើយ ពេលយួនវ៉ៃយកដីរំតាមភ្នំយើងទៅនៅដីថៃ ចុះនៅក្រោមបានមួយឆ្នាំដែរ បានគេដកគាត់ទៅលិច មានកំលាំងខ្លះទៅលិច ។

ដានីៈ	អ៊ំមានដឹងពេលដែលយួនវ៉ៃបានទាំងអស់យើងបានម្តុំ មកជិតៗគ្នា តាម៉ុក, តាសុន សេន នៅជិតៗគ្នា ពេលហ្នឹងគាត់២នាក់អីហ្នឹង ចុះសំរុងគ្នា ឬមិនចុះសំរុងគ្នា?

កូនៈ	អត់ដឹងដែរ ដល់ខាងលើ គាត់ឈប់ហើយលែងដឹងលឺ គាត់សុំគេសំរាក ។

ស៊ីមៈ	ខ្ញុំលែងដឹង ។

ដានីៈ	ហើយអីចឹងខ្ញុំចង់ដឹងពេលដែលអ៊ំចុះមក ចង់ដឹងពីប្រវត្តិយើងនៅត្រពាំងប្រាសាទយ៉ាងម៉េចដែរ ពេលដែលអ៊ំចុះមកដំបូងឆ្នាំ៨៩ហ្នឹង យើងចាប់ផ្តើមរៀបចំយ៉ាងម៉េច?

ស៊ីមៈ	៨៨យើងចុះមកនៅនេះ ។

កូនៈ	៨៩ចូល៩០ហើយ ។

ស៊ីមៈ	៩០បានពួកស្រេង ចុះទៅនៅកន្លែងនេះរាល់ថ្ងៃហ្នឹង ។

ដានីៈ	ខាងណា?

ស៊ីមៈ	នៅត្រពាំងប្រាសាទនេះពួកពិការទេទៅនៅកន្លែងហ្នឹងមុនគេ ហើយនិងពួក៨២ ។

កូនៈ	ហៅ៨០២ ។

ស៊ីមៈ	៨០២ ពីដើម៨២ តែឥឡូវគេហៅ៨០២ ។

ដានីៈ	គេបង្កើតកងពលថ្មី?

កូនៈ	គេបង្កើតថ្មី គេបំបែកពី៨០១ហ្នឹង ។

ដានីៈ	ដែលចុះដំបូងក្រុមពិការទេដែលនៅកន្លែងត្រពាំងប្រាសាទ ។

ស៊ីមៈ បាទ! នៅខាងនោះត្រពាំង ។

កូនៈ ខាងជើង ។

ដានីៈ ភាគច្រើនកងពល៨០២នៅម្តុំហ្នឹង?

ស៊ីមៈ បាទ! ៨០២ ។

ដានីៈ ហើយខាងនេះ ភូមិយើង?

ស៊ីមៈ ៨០១ ។

ដានីៈ ៨០១នេះវរៈប៉ុន្មានទៅដែលចូលមកនៅ?

ស៊ីមៈ នេះវរៈ៨១ ។

កូនៈ ៨១, នោះ៨៥, ៨៤នៅកន្លែងផ្សារទំនប់ដាច់រាល់ថ្ងៃ ។

ដានីៈ ៨៤កន្លែងផ្សារទំនប់ដាច់?

កូនៈ បាទ!

ស៊ីមៈ ដក៨២ចេញបាត់ហើយ គេធ្វើកងពលអស់ហើយ ។

កូនៈ ៨២គេដកទៅធ្វើ៨០២ អត់មានបាត់គេដកបំបែក ។

ដានីៈ ចុះ៨៣ មាន៨៣អត់?

កូនៈ ៨៣ក៏អត់មានដែរ គេរំលាយទៅក្នុងកងពល៨០១ គេហៅវរសេនាធំ៥៩, ៨៣ហ្នឹង ។

ស៊ីមៈ រំលាយអស់ ។

ដានីៈ ៨៣ទៅជាវរសេនាធំ៥៩វិញ?

ស៊ីមៈ ហ្នឹងហើយ ក្នុងវរសេនាធំ៨៣គេបំបែកមកជាមួយគាត់នេះពាក់កណ្តាល នៅនោះពាក់កណ្តាល ពាក់កណ្តាលគេធ្វើជាវរសេនាធំ៥៩ តែគាត់ប្រធានវរសេនាធំហ្នឹងគាត់ទៅខាងបារាំដែរ គាត់មានបញ្ហាទៅបារាំ ។

ដានីៈ ពីណាគេហ្នឹង?

ស៊ីមៈ ស្មីទេកាលហ្នឹង ។

កូនៈ បែបគ្នា ដល់ហ្នឹងឃើញកន្លែង ដល់នេះគេស្ម័គ្រចិត្ត ។

ដានីៈ គេមានបង្កើតវរសេនាធំថ្មីៗទៀតច្រើនដែលអត់ទេ?

កូនៈ អត់ទេមានតែដកបំបែកមកកងពលទៅឆ្ងាយៗ ។

ដានីៈ ដល់ពេលក្រោយមកពេលដែលចុះមកហ្នឹង អ៊ំនៅក្នុង៨១បានជាមកនៅនេះ៨១?

ស៊ីមៈ បាទ!

ដានីៈ ទទួល៨១វិញឬឈប់ហើយ?

ស៊ីមៈ ឈប់ហើយ ។

កូនៈ ឈប់ហើយ គ្រាន់តែនៅក្នុងក្រុមគ្រួសារកងទ័ពវរសេនាធំ៨១ ។

ដានីៈ អ្នកណាគេដែលទទួល៨១ក្រោយ?

ស៊ីមៈ ពួកអាភាម ក្មួយខ្ញុំ ។

កូនៈ អត់ទេ ហ្នឹងក្រោយ ពីណា គេបែកគ្នាយូរទៅភ្លេច ខ្វះស្លាប់អស់ហើយ ។

ដានីៈ អីចឹងអ៊ំយើងមកដំបូងយើងយ៉ាងម៉េច បានយើងដាក់កន្លែងហ្នឹងថាត្រពាំងប្រាសាទ ហើយដាក់ឈ្មោះភូមិ-ឃុំ យើងរៀបចំជាភូមិ?

ស៊ីមៈ ដាក់អីចឹង កន្លែងត្រពាំងប្រាសាទ វាមានត្រពាំងស្រាប់ហែរតាមប្រាសាទហ្នឹង មើលទៅឃើញប្រាសាទអីចឹង យើងដាក់ស្រុកត្រពាំងប្រាសាទ ។

ដានីៈ ហ្នឹងផ្ដួចផ្ដើមដាក់ អ៊ំអ្នកផ្ដួចផ្ដើមឬអ្នកណាដែលផ្ដួចផ្ដើមដំបូង?

ស៊ីមៈ មេៗទាំងអស់ហ្នឹងពិគ្រោះគ្នាហើយ រាយការណ៍ទៅលើ លើគេឯកភាពឲ្យដាក់អីចឹង ដល់មកមើល ។

ដានីៈ ឆ្នាំណាទៅអ៊ំដែលគេ?

ស៊ីមៈ ឆ្នាំយើងមើល ឆ្នាំដែលចុះមកនៅពេញទាំងអស់ ម៉ិញថា៩១ ។

ដានីៈ ចាំមើល៨៩យើងចុះមក ។

ស៊ីមៈ ៨៩យើងចុះ ។

ដានីៈ ៩១?

ស៊ីមៈ ៩១ហ្នឹងឯងដាក់ឈ្មោះត្រពាំងប្រាសាទ ហើយកន្លែងនេះទំនប់ហ្នឹងវាដាច់ ទំនប់ចាស់ដែលទេ ទំនប់យើងនឹងវត្ត ។

ដានីៈ ទំនប់ហ្នឹងមិនមែនតា០៥ អ្នកធ្វើទេ?

ស៊ីមៈ ហ្នឹងទប់ក្រោយទៀតទេ តែទំនប់ចាស់គេ ស្នាមគេអីចឹង សំដៅមកប្រាសាទយើងនេះ ។

ដានីៈ បានន័យថាទំនប់បុរាណគេ ។

ស៊ីមៈ បុរាណគេដល់យើងទប់ស្កាត់ទៅ៨៦ យើងទប់ដោយដៃទេ ទំនប់គេថាបណ្ដោយសាលារៀនអាហ្នឹង តែប៉ុណ្ណឹងទេទំបន់គេ ។

ដានីៈ ដល់ពេលទំនប់ហ្នឹងដាច់យើងទប់ទៅ?

ស៊ីមៈ ហ្នឹងហើយ ។

ដានីៈ ទប់ហើយដាច់ទៀតឬយ៉ាងម៉េច?

ស៊ីម៖ ហ្នឹងហើយដាច់ទៀត។ ដល់ហើយហៅទំនប់ដាច់ គេពីមុនក៏ដាច់ យើងទប់ក៏ដាច់ ដាក់ទំនប់ដាច់អីចឹងទៅ។

ដានី៖ តែពីមុនហ្នឹងមាន បើតាមអ៊ំដឹង កន្លែងហ្នឹងមានភូមិគេរស់នៅទេ កាលពីមុនមក?

ស៊ីម៖ ពីមុនអត់មានទេ មានតែប្រាសាទចាស់ អត់មានស្អីចាប់អារម្មណ៍រឿងប្រជាជននៅអត់ទេ ខ្ញុំនិយាយរឿងអូរមេម៉ាយហ្នឹងបានមានផ្ទះ ប្រហែលជាផ្ទះ១ឬ២តែប៉ុណ្ណឹងទេ។

ដានី៖ អូរមេម៉ាយនៅកន្លែងណាទៅ?

ស៊ីម៖ អូរមេម៉ាយកន្លែងស្ពានដាច់គេកំពុងធ្វើរាល់ថ្ងៃ។

ដានី៖ ហ្នឹង?

ស៊ីម៖ ហ្នឹងហើយ។

ដានី៖ កន្លែងស្ពានដាច់?

ស៊ីម៖ ហ្នឹងហើយ។

ដានី៖ ហ្នឹងក្នុងឃុំបាក់អន្លង់?

ស៊ីម៖ បាក់អន្លង់ហ្នឹង ហ្នឹងអូរមេម៉ាយ។

ដានី៖ អូរមេម៉ាយពីមុនដែលអ៊ំចុះមកមានផ្ទះគេនៅហ្នឹង?

ស៊ីម៖ ឃើញតែកន្លែងទេ មានដើមអំពិល ដើមស្វាយ សន្និដ្ឋានថាពីដើមពួកខូចវានៅជាស្នាក់ការលក់ចេញ ទិញចូលពីរឿងលួចគោ លួចក្របី ដោះដូរគ្នាដូចយើងទល់ដែនយួន។

ដានី៖ និយាយឲ្យចំថាពួកចោរ?

ស៊ីម៖ ពួកចោរ បើថាយើងអន្លង់វែងបានមានភូមិគេ មានដើមដូងពិតប្រាកដ នេះសុទ្ធតែព្រៃទាំងអស់ទេ អត់មានស្អីទេ។

ដានី៖ អីចឹងពីឆ្នាំ៩១អ៊ំមានប្រសាសន៍ថាពីឆ្នាំ៩១ យើងចាប់ផ្ដើមមូលមតិគ្នាបង្កើតឈ្មោះជាស្រុកត្រពាំងប្រាសាទ ដំបូងយើងចុះមកយើងមានតែអន្លង់វែងមួយទេ។

ស៊ីម៖ មានអន្លង់វែងទេ កន្លែងគេមានតាំងពីដើមមកអាហ្នឹងអន្លង់វែង មានផ្ទះ ដូងគេនៅផ្ដែ។

ដានី៖ ប៉ុន្តែម៉េចបានជាយើងមានគំនិតបំបែកស្រុក ដូចថាបំបែកជាស្រុក២តំបន់ហ្នឹង?

ស៊ីម៖ អានោះបំបែកស្រុកហ្នឹងគឺយើងបំបែកពីមុនមកហើយ ដល់យើងត្រូវរ៉ូវគ្នាជាមួយរាជរដ្ឋាភិបាលទៅ ឯកភាពដាក់ស្រុក២អីចឹងទៅ។

ដានី៖ តែយើងបំបែកតាំងពីមុនម្ល៉េះ តាំងពីឆ្នាំ៩១?

ស៊ីម៖ មុនហើយៗ តាំងពីឆ្នាំ៩១មក។

ដានី៖ ម៉េចបានយើងមានគំនិតថាយើងបំបែកអីចឹង?

ស៊ីម៖ បំបែកបានន័យថា កន្លែងនេះយើងត្រូវដាក់ប៉ុន្មានកងពល ទំនប់ដាច់នេះ ស្រុកត្រពាំងប្រាសាទនេះ ដាក់ប៉ុន្មានកងពល មាន៨០១, ៨០២ ហើយនិងកងអីញ៉ូន អាដល ។

ដានី៖ កងតាញ៉ូន?

ស៊ីម៖ តែតាញ៉ូន គេយកទៅអន្លង់វែងទេ ។

ដានី៖ ៦១៦ ។

ស៊ីម៖ ៦១៦ ទេនៅក្នុងស្រុកនេះដែរ ៣កងពលហ្នឹង មួយស្រុកត្រពាំងប្រាសាទនេះ ហើយនោះគេប៉ុន្មានកងពលដែរ ។

ដានី៖ ចុះកងពលរបស់តាជុំ?

ស៊ីម៖ នេះ៨កងពលដែរ ជុំ ដែលនេះ ។

ដានី៖ កងពលរបស់តាជុំ ហើយនិងកងពលរបស់តាហឿន?

ស៊ីម៖ កងលេខប៉ុន្មានទេភ្លេចអស់អាដល តាហឿន អឺ, ជុំ ជាមួយតាម៉េត កំបុតជើង កត់នេះច្បាស់ថែម ។

ដានី៖ ខ្ញុំជួបគាត់ដែរ តែខ្ញុំចង់ជួបឲ្យច្រើន ។ ក្រោយមកដល់ពេលយើងបំបែកអីចឹងហើយក្រោយមកយ៉ាងម៉េចដែរ ពេលដែលចុះមកឆ្នាំ៩១ អ៊ំមានប្រសាសន៍ថាគេចាប់ផ្ដើមបំបែកជាស្រុក អីចឹងមានចាត់តាំងថាអ្នកណាគ្រប់គ្រងស្រុក អ្នកណាគ្រប់គ្រងទាហាន គេមានបែងចែកអីចឹងអត់?

ស៊ីម៖ បែងចែក ភ្លាមមកដកប្អូនជុំ ទទួលខាងស្រុក ហើយលោកប្អូនជុំហ្នឹងវាហៅខ្ញុំទៅនៅកន្លែងស្រុករហូតដែរ ។

ដានី៖ អ៊ំខាងអីវិញកាលហ្នឹង?

ស៊ីម៖ ខ្ញុំគេឲ្យទទួលសាលា គ្រប់គ្រងសាលាស្រុកហ្នឹងឯង ។

ដានី៖ សាលាស្រុកដំបូងគេ?

ស៊ីម៖ មន្ទីរ ។

ដានី៖ សារមន្ទីរស្រុក?

ស៊ីម៖ ហ្នឹងហើយ ដល់នេះបានយើងស្រួលបួលជាមួយរាជរដ្ឋាភិបាល គេសំរេចធ្វើសមាហរណ-កម្មហើយ ខ្ញុំលាឈប់ទាំងអស់ ខ្ញុំថាខ្ញុំឈប់ហើយ ខ្ញុំចាស់ហើយខ្ញុំអត់ធ្វើអីទេ បើខាងសាសនាខ្ញុំទទួល ។

ដានី៖ ថាអីចឹងវិញ?

ស៊ីម៖ ហ្នឹងហើយ ហើយបានគេដាក់ខាងសាសនារហូត ។

ដានី៖ ខាងធម្មការ?

ស៊ីម៖ ហ្នឹងហើយ ។

ដានី៖ នៅការិយាល័យធម្មការស្រុក?

ស៊ីម៖ នៅការិយាល័យ ។

ដានី៖ ឥឡូវក៏អ៊ំនៅប្រធានការិយាល័យធម្មការដែរ?

ស៊ីម៖ នៅស្វាត់ឈឺង កំណត់ជាមួយនាយកនៅអន្លង់វែង ខ្ញុំឈប់ធ្វើប្រធាន ខ្ញុំឈប់ទាំងអស់ដឹកនាំអី ឲ្យក្មេងៗគេធ្វើចុះ ខ្ញុំបើខាងសាសនាហ្នឹងខ្ញុំធ្វើ ដល់អីចឹងល្អ ។

ដានី៖ សម្ដេចនាយកហ៊ុនសែន?

ស៊ីម៖ ហ្នឹងហើយគេចាប់ផ្ដើមបញ្ជូន ។

ដានី៖ អ៊ំបាននិយាយជាមួយគាត់ដែរ ។

ស៊ីម៖ ផ្ទាល់នៅអន្លង់វែង ។

ដានី៖ គាត់ចាត់តាំងអ៊ំប្អូយ៉ាងម៉េចបានអ៊ំ?

ស៊ីម៖ បាននេះ អីចឹងល្អហើយ ទៅរៀនកន្លែងក្រសួងគេសុខ អាន ខ្ញុំទៅរៀនហ្នឹងមួយខែ រៀនហើយធ្វើក្រិត្យហើយអស់បានមក ។

ដានី៖ អ៊ំមួយទៀតដែលអ៊ំមានប្រសាសន៍មិញ ខ្ញុំចាប់អារម្មណ៍ទាក់ទងពីកន្លែងដែលខាងខ្មែរក្រហមយើងបែកបាក់គ្នា ចាប់ផ្ដើមមូលហេតុដែលបែកបាក់ហ្នឹងមកពីយ៉ាងម៉េចដែល បើតាមអ៊ំយល់?

ស៊ីម៖ បែកបាក់មកពីច្រណែនគ្នា គ្មានអីជាងច្រណែនគ្នា ។

ដានី៖ ច្រណែនគ្នាយ៉ាងម៉េចវិញទៅ?

ស៊ីម៖ ច្រណែនដូចជាបង០៥ គាត់ពូកែខាងវៃ ធ្វើអីទាំងអស់ វៃអន្លង់វែងដែលចាញ់អស់ហើយខាងបង០៥ទេដែលវៃបានឈ្នះវិញកាលនោះ ។ អីចឹងទៅខាងលើ ប៉ុល ពត គាត់ចង់លើក០៥ ដល់អីចឹងវាច្រណែនគ្នា អាមីអាថៅងវាច្រណែនគ្នាបើកឡានបុកបង្ហោលភ្លើងងាប់អស់មួយសារហ្នឹង ។

ដានី៖ ពីណា?

ស៊ីម៖ អាគេម ។

ដានី៖ បើកឡានដោយសារគាត់ខឹងច្រណែន?

ស៊ីម៖ អត់ទេ ស្រវឹង ហើយម្យ៉ាងត្រូវហ្នឹងអីចឹងផង កាលពីនៅក្រមើលឃើញគ្នា ដល់ពេលមានលែងស្គាល់គ្នាឯងអស់ ត្រូវស្លាប់ និយាយលេងអូន ងាប់អស់ ។

ដានី:　　ដល់អីចឹងបើតាមអ៊ំមានប្រសាសន៍ហ្នឹងគឺកើតចេញពីប្រណែនគ្នាទេ?

ស៊ីម:　　ប្រណែនគ្នាមុខមាត់បុណ្យសក្តិ ។

ដានី:　　ដោយសារតាប៉ុល ពត គាត់ប្រុងរៀបចំឲ្យតា០៥ ធ្វើជាមេទ័ពធំ ដល់ពេលអីចឹងតាម៉ុក ប្រណែន ឬខាងកងពលប្រណែន?

ស៊ីម:　　ខាងគាត់ហ្នឹងឯងប្រណែន ដល់នេះមានឈ្លោះជាមួយ០៥ហើយ បើអីចឹងឯងកំទេចចោល ចាប់យកមកដាក់គុក ចោទបេះ ចោទចុះទៅ ។

ដានី:　　បើតាមអ៊ំការស្លាប់របស់តាសុន សេន មិនមែនតា០៥ អ្នកសម្លាប់ទេ?

ស៊ីម:　　អត់ទេ ។

ដានី:　　បើតាមអ៊ំយ៉ាងម៉េចវិញ អ៊ំមានប្រសាសន៍កន្លែងហ្នឹង?

ស៊ីម:　　ខ្ញុំនិយាយមុិញហ្នឹង សម្លាប់ងាប់បាត់ហើយ ។

ដានី:　　ពីណាគេ?

ស៊ីម:　　ដែលបើកបុកបន្តោលខ្សែភ្លើង ។

ដានី:　　ឈ្មោះតេម ហ្នឹង?

ស៊ីម:　　តេម ហ្នឹងឯង ។

ដានី:　　អ៊ំមានអីដែលជាសំអាងថាតេម អ្នកសម្លាប់តា០៥?

ស៊ីម:　　វាស្អប់បង០៥ អានេះយើងនិយាយលេងមិនមែនយកសាច់ការទេ អាហ្នឹងដាក់ស្តែងគឺ អីចឹង ឥឡូវយើងសួរមើលទៅគ្រប់ទាំងអស់ អ្នកណាដែលធ្វើបាប ។

ដានី:　　វាចេះអ៊ំកាលខ្ញុំទៅជួបអ៊ំពូមីងដែលខាងអន្លង់វែង គាត់មានប្រសាសន៍ថាអ្នកដែលសម្លាប់ តាសុន សេន គឺតាប៉ុល ពត បញ្ជាឲ្យតា០៥ទៅសម្លាប់ តាសុន សេន។ ដោយសារតា សុន សេន គាត់មានការចរចារសម្ងាត់ជាមួយរាជរដ្ឋាភិបាល ហើយប្អូនគាត់នៅខាងភ្នំព្រឹក តានី កន គាត់ចូលជាមួយរាជរដ្ឋាភិបាល តាប៉ុល ពត ចាប់សំបុត្របាន ហើយបញ្ជាឲ្យ តា០៥ហ្នឹងទៅសម្លាប់តាសុន សេន ហើយតា០៥ មានគំនុំជាមួយតាសុន សេន យ៉ាងម៉េចកាលពីជំនាន់៣ឆ្នាំ ហើយក៏សម្លាប់តាសុន សេន និងក្រុមគ្រួសារទៅ អានេះ ខាងអន្លង់វែងគេនិយាយ ។

ស៊ីម:　　អាហ្នឹងអីចឹងហើយ ខាងនោះគេចោទអីចឹង ។

ដានី:　　បើតាមអ៊ំ អ៊ុំយល់ឃើញ?

ស៊ីម:　　អត់ទេ ការពិតមិនមែនអីចឹង ។

ដានី:　　ការពិតមិនមែនអីចឹងទេ?

ស៊ីម: មិនអីចឹង ។

ដានី: បើតាមការពិតអ៊ំគិតថាយ៉ាងម៉េចវិញ?

ស៊ីម: គិតថាហ្នឹងធ្វើទៅដើម្បីចោទយកឲ្យបាត់បណ្ដោយ ។

ដានី: អ៊ំមានប្រសាសន៍មុនហ្នឹង ថ្ងៃតាសុន សេន ស្លាប់ហ្នឹងតា០៥ នៅជាមួយអ៊ំទេ?

ស៊ីម: នៅនេះទេ ។

ដានី: ហើយតា០៥ មានប្រសាសន៍ជាមួយអ៊ំយ៉ាងម៉េចទៀតកាលហ្នឹង?

ស៊ីម: មានគេធ្វើរដ្ឋប្រហារអ៊ំសុន សេន ហើយ គាត់ទៅមើល ហើយខ្ញុំកាលហ្នឹងខ្ញុំគ្រុនទៅអត់រួចទេ ម៉ោងជិត៧ហើយ ។

ដានី: ៧ព្រឹក?

ស៊ីម: ហ្នឹងហើយ គាត់ទំនេរ គាត់ថាទៅមើល អាណាគេធ្វើអីចឹង គាត់ទៅៗ ខ្ញុំអត់ទៅ ។

ដានី: ហើយដល់ពេលគាត់យប់គេសម្លាប់តាសុន សេន ដល់ព្រលឹមឡើងបានជួបអ៊ំ ហើយប្រាប់អ៊ំអីចឹង ជួបនៅកន្លែងណា?

ស៊ីម: ជួបនៅហ្នឹងអូរស្វាយ ។

ដានី: កាលហ្នឹងអ៊ំនៅអូរស្វាយ?

ស៊ីម: ហ្នឹងហើយ ដកពីនេះទៅនៅហ្នឹងទៀត ។

ដានី: ម៉េចអីចឹង ម៉េចបានដកពីនេះទៅ?

ស៊ីម: កាលហ្នឹងយួនវាចូលមកវៃដំបូង?

ដានី: វៃទៅយើងដកចេញពីហ្នឹងទៀត?

ស៊ីម: ដកចេញពីហ្នឹងទៅនៅអូរស្វាយ ។

ដានី: ទៅនៅជុំគ្នានៅអូរស្វាយ?

ស៊ីម: អន្ទង់វែងវាអត់អី ដល់គេវៃអន្ទង់វែងវិញ បានចេញពីអូរស្វាយមកនៅនេះវិញ ។

ដានី: ច្រើនដំណាក់ណាស់ ។ ដល់ក្រោយមកទៀត តាសុន សេន ស្លាប់ទៅ ហើយតាម៉ុក ចាប់ផ្ដើមកំលាំងវៃជាមួយតាប៉ុល ពត, តា០៥ ម៉េចបានជា?

ស៊ីម: ចុះដឹងថាប៉ុល ពត អស់កំលាំងហើយ វៃ បានធ្វើបាបចាប់បណ្ដោយ ។

ដានី: អស់កំលាំងម៉េចអ៊ំ?

ស៊ីម: ចុះប៉ុល ពត មានកំលាំងទ័ពពីណាទៀត ។

ដានី: ក្រែងកំលាំងតា០៥, ០៦ នៅ?

ស៊ីម: ហ្នឹងមកចាប់តា០៥, ០៦ អស់ហើយ ។

ដានីៈ អ៊ឹមានប្រសាសន៍ថាតា០៥, តា០៦ គាត់ពូកែខាងធ្វើសង្គ្រាម ខាងវ៉ៃ គាត់ពូកែ ហើយ គាត់មានកងពលរបស់៨០១, ៨០២, ៩២០ កំលាំងគាត់មានម៉េចគាត់អត់តតាំង ជាមួយតាម៉ុក ឲ្យតាម៉ុក វ៉ៃឈ្នះ?

ស៊ីមៈ តម៉េចជាមួយមេ អត់ជឿទេ ខ្ញុំប្រាប់ថាតែក បងកុំជឿថា ខ្មោចខូន ខ្ញុំប្រាប់ ខូន អ្នកទៅ ជាមួយ ៗ នាំអាតពីខូន នាំអាតពីខេមរា ហៅឲ្យបង០៥នាំតាៗចុះមក កុំអីបង០៥ គាត់ អត់មកទេ ដល់អីចឹងទៅថា តា អត់ធ្វើអីទេ ជន្ទងបង០៥អីហ្នឹង ។

ដានីៈ ពីណាជន្ទង? តាសាន?

ស៊ីមៈ តាសាន ហ្នឹងអត់អីទេ តា ណាសម្ងាប់យើងចូលមក ចុះមក អេ៎! អត់ទៅទេ ដល់យាយ ញ៉ូន ទៅអន្លូរទៀតបានមកហ្នឹង មកទៅគេចាប់ចងផ្ទះញ៉ូន ទៅបាត់ ។

ដានីៈ ផ្ទះតាញ៉ូន កងពលហ្នឹង?

ស៊ីមៈ ហ្នឹងហើយ ញ៉ូន កងពលកាលហ្នឹងគេនៅភូមិផ្អាវ ។

ដានីៈ ពីណាមកចាប់ចង?

ស៊ីមៈ បើកឡានទៅដល់ហ្នឹងគេចងហ្នឹងទៅ ចងបង០៥, ០៦ ។

ដានីៈ គេចាប់ពីកន្លែងណាមក?

ស៊ីមៈ ចុះពីលើភ្នំមកហ្នឹង ចុះតាមអូរស្មាយ ។

ដានីៈ អ៊ឹបានឃើញទេគេចាប់ចងគាត់?

ស៊ីមៈ អីមិននៅ បើខ្ញុំនៅអូរស្មាយដែរ បរឡានមកតាមហ្នឹងមើលលាន់ ។

ដានីៈ តាខូន គេចាប់ដែរ?

ស៊ីមៈ ចាប់ដល់ផ្ទះញ៉ូន នោះបានគេចាប់ ។

ដានីៈ ចាប់ប៉ុន្មាននាក់ទៅតាមអ៊ឹចាំ?

ស៊ីមៈ ចាប់ខេមរា ចាប់អីទាំងអស់ ។

ដានីៈ ចាប់ខេមរា, ខូន, ០៥, ០៦?

ស៊ីមៈ ហើយនិងនេះមួយទៀត ជាមួយ០៥ កងវរសេនាធំ អស់ប៉ុន្មាននាក់ សែន មួយទៀត សុទ្ធអ្នកវ៉ៃ សុទ្ធតែជំនាញ ។

ដានីៈ ចាប់៥នាក់កាលហ្នឹង? ខូន, ខេមរា, សែន, ០៦ និង០៥?

ស៊ីមៈ ហ្នឹងហើយ ។

ដានីៈ ហើយនិងយាយណូន មួយទៀត?

ស៊ីមៈ យាយណូន ។

ដានី៖ យាយណូន គេចាប់ទៅដែរ?

ស៊ីម៖ គេចាប់យកទៅវ៉ៃចោល ចៅតាម៉ុក ហ្នឹងតែម្ដង យាយណូន។

ដានី៖ ចុះប្រពន្ធរបស់០៦ ម៉េចបានគេអត់ធ្វើអី?

ស៊ីម៖ ប្រពន្ធ០៦អត់ទៅ យាយណូន សុខចិត្តស្លាប់ជាមួយប្ដី។

ដានី៖ យាយណូន គាត់សុខចិត្តស្លាប់ជាមួយប្ដី?

ស៊ីម៖ គាត់មិននៅទេ ០៥ទៅណាគាត់ទៅហ្នឹង ដាច់ខាតអីចឹងតែម្ដង។

ដានី៖ បើតាមយោបល់អ៊ំតាម៉ុក គាត់មានចំណែក?

ស៊ីម៖ ហ្នឹងហើយ។

ដានី៖ តាម៉ុក ហើយនិងតាប៉ុល ពត អ៊ំគិតថាមួយណាខុស មួយណាត្រូវ? បើខាងអន្លង់វែងគេថាដោយសារប៉ុល ពត ក្បត់សម្លាប់តាសុន សេន យ៉ាងម៉េច? តែបើតាមយោបល់អ៊ំ អ៊ំគិតថាយ៉ាងម៉េចវិញ តាម៉ុក ហើយនិងតាប៉ុល ពត គាត់ឈ្លោះគ្នានេះ?

ស៊ីម៖ អានេះវានៅលើជំនឿរបស់គេទេ តែយើងអត់ គាត់ស្រឡាញ់គ្នាណាស់ អ៊ំប៉ុល ពត ហើយនិងសុន សេន មានការអីហៅទៅពិគ្រោះគ្នារហូតជាប់ អត់ដែលនេះទេ។

ដានី៖ តែអ៊ំអត់ជឿទេ?

ស៊ីម៖ មិនជឿទេ ខ្ញុំមិនជឿទេ។

ដានី៖ អ៊ំជឿថាកំហុសនេះកំហុសរបស់អ្នកណា ដែលធ្វើឲ្យបែកបាក់នេះ?

ស៊ីម៖ កំហុសនេះមកពីតាមុត។

ដានី៖ តាមុត គាត់នៅនោះហ្នឹង?

ស៊ីម៖ ហ្នឹងហើយ ទាក់ទងហៅ កាលហ្នឹងតាម៉ុក ទៅតាមុត នោះ បានវិលមកវិញរឿងអីចឹងទៅ រឿងហ្នឹងអីចឹងតែយើងមិនបាច់ទេ នេះចង់ប្រាជ្ញឲ្យឃើញទេ។

ដានី៖ ដល់ពេលគេចាប់០៥, ០៦, ខេមរា, ខួន, សែន ទៅបាត់អស់ហើយ ព្រឹត្តិការណ៍ហ្នឹង យ៉ាងម៉េចទៀតទៅ?

ស៊ីម៖ ព្រឹត្តិការណ៍ហ្នឹងគេចាប់យកទៅហើយ បានមកចាប់ប្រពន្ធកូនទៅទៀត ចាប់យកទុកអន្លង់វែង ប្រពន្ធកូនពួកអ្នកទៅនោះ រត់ទៅរករដ្ឋាភិបាល ពួកហ្នឹងលោកលាង រត់ទៅ។

ដានី៖ អ៊ំអត់មានចូលទៅជាមួយ?

ស៊ីម៖ អត់ទៅទេ តែគេប្រាប់ឪ ឥឡូវតាឲ្យខ្ញុំទៅលិចមិនបាច់យកអាហារ មិនបាច់យកអីទៅទេ នីរសាមិនបាច់ទេ ទ័ពនោះមានហើយ ម៉េចឲ្យខ្ញុំទៅមិនឲ្យ។ ខ្ញុំថា ឯងកុំប្រកាន់អញ អញនិយាយត្រឹមត្រូវទេ ឥឡូវពេលនេះវាដល់ហើយ មេយើងអស់ហើយ នៅតែយើងទេ បើ

ឯងចង់ល្អថ្ងៃរះណាទៅហ្នឹងទៅៗ មែនទេឪ? អើ! ថ្ងៃរះណាទៅហ្នឹងទៅៗ ជុំ គេទៅអស់ ហើយតា៎ នៅតែលាង ឯង កាលហ្នឹងជុំ គេនាំគ្នាទៅមុនៗ

ដានី: តាជុំ, តាកែវ អីទៅអស់?

ស៊ីម: ទៅៗ

ដានី: តាកែវ កាន់វរសេនាធំដែលអត់ទេកាលហ្នឹង?

ស៊ីម: វរសេនាធំ ចូលកងពលហើយៗ

ដានី: ដល់ពេលទៅអីចឹង តាលាង មកសួរយោបល់អ៊ំ? សួរហើយបានគាត់ទៅខាងរដ្ឋាភិបាល ដែរទៅ?

ស៊ីម: ចុះតាម៉ុក បញ្ជូនឲ្យទៅលិច រួចលិចវាអត់មេ លេសរបស់គេបំបែកៗ

ដានី: ទៅលិចទៅនៅណា?

ស៊ីម: ទៅនៅម៉ាឡៃ, ប៉ៃលិន ទៅជាមួយពួកនោះៗ

ដានី: ដូចថាខាងលិចគេបញ្ចូលជាមួយរដ្ឋាភិបាលអស់ហើយ គាត់ចង់បញ្ជូនកងទ័ពមួយចំនួយឲ្យ ទៅកាន់នៅខាងលិច?

ស៊ីម: ហ្នឹងហើយទៅខាងលិចៗ

ដានី: ដល់ពេលអីចឹងអ៊ំ?

ស៊ីម: ដល់ហើយមកសួរខ្ញុំ ខ្ញុំថាអត់ទេ បើថាយកល្អថ្ងៃរះត្រង់ណាទៅហ្នឹង ហ្នឹងវាល្អ ម៉េចក៏បាន ក្តីដែរ ដល់ទៅគេចាប់ប្រពន្ធកូនយកទៅដាក់អន្លង់វែងអស់ៗ

ដានី: គេចាប់ប្រពន្ធកូនទៅដែរ?

ស៊ីម: គេចាប់ប្រពន្ធកូនវា ចាប់យកទៅ យំអើងអាប់ បានវាតាមតារចេះតែធ្វើអីស្រែកមកដាក់ តា ឲ្យយកប្រពន្ធឲ្យវា តែបាត់អត់បានទេ អាហ្នឹងចុងបញ្ចប់ហើយ អីចឹងបានវាមកតែម្តង គ្នាវាទាំងប៉ុន្មានមកវៃយកប្រពន្ធហ្នឹងៗ ដល់មកដល់ត្រឹមហ្នឹងកងទ័ពរាជរដ្ឋាភិបាលក៏គេមក តាមក្រោយមកជួយដែលទៅ មកដល់ចាប់ដៃគ្នានៅទំនប់ដាច់ វៃគ្នាហ្នឹងទៅតាម៉ុក ចាញ់ មានកំលាំងណា បើ៩២០ក៏វាត្រូវខាងជ័យជំនះអស់ហើយៗ

ដានី: ចាញ់បណ្តោយ?

ស៊ីម: កងពីម មកនេះអស់ៗ

ដានី: កាលហ្នឹងតាពីម គាត់នៅ៩៨០អីដែលអត់ កាលអ៊ំមកដំបូង?

ស៊ីម: ៩៨០ៗ

ដានី: កាលហ្នឹងគាត់ជាគណៈកងពលជាមួយអ៊ំដែរ?

ស៊ីមៈ ពីដឹបូនជាមួយគ្នា ដល់នេះទៅបានខ្ញុំចេញមកវិញវាឡើងនៅហ្នឹង ។

ដានីៈ ពីម, តាឌី ធីន ?

ស៊ីមៈ ហ្នឹងហើយ ។ ដល់នោះក៏ផ្អើលដែរទៅ វៃបកទៅតាម៉ុក វិញ នេះក៏វៃទៅ តាម៉ុក រត់ទៅលើភ្នំ ។

ដានីៈ អ៊ឹទាក់ទងពីរឿងរ៉ាវកាលជំនាន់យើងធ្វើសង្គ្រាម ការរស់នៅ ការប្រតិបត្តិតាមសាសនាប្រពៃណី យ៉ាងម៉េចដែរ? ហើយយើងបន្ទាប់ពីសមាហរណកម្មហើយ ម៉េចដែរ? ការរស់នៅ ការប្រតិបត្តិសាសនាវាមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ?

ស៊ីមៈ កាលសម័យមុននោះ ដូចយើងដឹងស្រាប់ហើយ ខ្មែរក្រហមអត់មានសាសនាទេ សូន្យអស់ហើយតាំងពីឆ្នាំ៧៣មកបញ្ចប់អស់ហើយ៧៤ ខាងវត្ត ខាងលោក ហៅឲ្យសឹកទៅជួយរំដោះជាតិវិញ សម័យនោះ ។ យើងធ្វើខ្ញុំបារាំងអស់ប៉ុន្មានកៅសិបប៉ុន្មានឆ្នាំហើយ ឥឡូវយើងចង់ធ្វើខ្ញុំអាមេរិកទៀតឬមួយយ៉ាងម៉េច ។ យើងក៏អស់ដែលទៅតាម ធ្វើម៉េចដើម្បីឈ្នះ តែគ្រាន់តែវិន័យធ្ងន់ជាងព្រះសង្ឃនោះទៅទៀត អត់ឲ្យប៉ះពាល់ទៅទៀត ម្ទេស១ផ្លែក៏មិនឲ្យលួច សុំគេដោយត្រង់បើគេឲ្យក៏យក ក៏មិនឲ្យកុំ ។

ដានីៈ អ៊ឹកាលជំនាន់៣ឆ្នាំម៉េចបានគេអត់ឲ្យមានសាសនា មានព្រះពុទ្ធសាសនា?

ស៊ីមៈ បើសាសនាអត់មនុស្សវៃ ។

ដានីៈ យើងជ័យជំនះហើយ ពេលដែលយើងឈ្នះអាមេរិកហើយ ហេតុអីយើងអត់បង្កើតឡើងវិញ?

ស៊ីមៈ មិនដឹងម៉េច បែបបំបិទតែម្តង ម៉េចគេហៅថា ហើយទំនាយវាត្រូវអីចឹងផង ពុទ្ធទំនាយថាអ៊ីៗហើយអស់ហើយមកដល់ត្រឹម ស្តេចពាលសោយរាជ្យអត់សាសនា ។

ដានីៈ អ៊ឹគិតថាពីណាស្តេចពាលសោយរាជ្យ?

ស៊ីមៈ ស្តេចពាលខ្មែរក្រហមហ្នឹងពាល ដឹកនាំគ្មានសាសនាអីណា អត់តែឯងទោលហ្នឹង បើមានសាសនាមានប្រឆាំងគ្នា ជួយរកកន្លែងត្រូវ ហើយហ្នឹងអត់ ។

ដានីៈ អ៊ឹថាអីចឹងដែរ?

ស៊ីមៈ ខ្ញុំគិតថាអីចឹង គិតពិចារណាក្នុងពុទ្ធទំនាយ ឥន្ទទំនាយ វាត្រូវមែន ហើយសោយរាជ្យបានតែប៉ុន្មានឆ្នាំ ប៉ុន្មានខែ ប៉ុន្មានថ្ងៃតែប៉ុណ្ណឹងឯង វារំលាយឯង ។

ដានីៈ អ៊ឹគិតថាពួកគាត់ដឹកនាំខុសដែរ?

ស៊ីមៈ ខុស ខុស ចប់ហើយក៏គ្មានស្អី នៅឯករាជ្យម្ចាស់ការ ធ្វើខ្លួនឯង ។

ដានីៈ ពេលអ៊ឹនៅរតនគិរី អ៊ឹមានអារម្មណ៍ភ័យខ្លាច គេចាប់ដែរ?

ស៊ឹមៈ អត់ទេ ខ្ញុំអត់មានព្រួយអីទេ ។

ដានីៈ ដល់ពេលយើងតស៊ូនៅតាមព្រំដែនហើយ យើងមាននៅប្រតិបត្តិតាមសាសនា បុណ្យទាន ចូលឆ្នាំ ទៅវត្ត ទៅវ៉ា ឬអត់ទេ?

ស៊ឹមៈ ទៅជាប់ដល់យើងចប់ហើយមានស្អី កសាងវត្ត ។

ដានីៈ ហ្នឹងពេលដែលយើងផ្តាច់ខ្លួនហើយចូលជាមួយរដ្ឋាភិបាលហើយ យើងចាប់ផ្តើមកសាងវត្តឡើងវិញ?

ស៊ឹមៈ ហ្នឹងហើយ ។

ដានីៈ ពេលនៅលើភ្នំអត់ទេ?

ស៊ឹមៈ អត់ទេ អត់មានទេ តែលោកយើងទៅដែរលោកថៃនៅលើភ្នំចេះតែទៅធ្វើនឹងគេ ។

ដានីៈ បានទៅដែរ?

ស៊ឹមៈ ទៅ ។

ដានីៈ តែកាលហ្នឹងតា១ គាត់អត់ហាមឃាត់ទេ?

ស៊ឹមៈ អត់ហាមទេ ទៅនៅជាប់ប្រទេសគេហើយ យើងមិនទៅគេម៉េច ទៅបុណ្យទៅចូលនឹងគេ ។

ដានីៈ អ៊ំអត់គាំទ្រទេនេះ អត់មានសាសនាអីហ្នឹង?

ស៊ឹមៈ អីចឹងហើយ បើយើងគាំទ្រតែយើងក៏យើងមិនអាចរស់បាន យល់ទេ ។

ដានីៈ បាទ!

ស៊ឹមៈ ចេះតែទ្រាំ ដល់ចប់ហើយដូចខ្ញុំថាអីចឹង ទាហានខ្ញុំឈប់ធ្វើហើយ បើចប់អស់ហើយ ឥឡូវគិតពីរឿងសាសនាវិញ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានជួយបានល្អ ។

ដានីៈ អ៊ំធ្វើជាមេខាងសាសនានៅត្រពាំងប្រាសាទ តាំងពីឆ្នាំណាមក?

ស៊ឹមៈ ធ្វើតាំងពីយើងសមាហរណកម្មហើយបាន១ឆ្នាំ ។

ដានីៈ ឆ្នាំ២០០០?

ស៊ឹមៈ ហ្នឹងហើយ ។

ដានីៈ ជំនាន់តាជុំ ជាតិ គាត់ធ្វើជាចៅហ្វាយស្រុក?

ស៊ឹមៈ ហ្នឹងហើយចៅហ្វាយស្រុក ។

ដានីៈ អ៊ំចាប់ផ្តើមធ្វើខាងសាសនា?

ស៊ឹមៈ ធ្វើរហូត បូជា ។

ដានីៈ អ៊ំទៅវត្តរៀងរាល់?

ស៊ឹមៈ ទៅជាប់ហ្នឹង ។

ដានីៈ រាល់ថ្ងៃ?

ស៊ីមៈ អត់ទេ អត់រាល់ថ្ងៃទេ ថ្ងៃសីល បុណ្យទានមិនដែលខានទេ ។

ដានីៈ អ៊ំរាល់ថ្ងៃកាន់សីលប៉ុន្មានហើយ?

ស៊ីមៈ ខ្ញុំអត់ទេ ខ្ញុំអត់កាន់នឹងគេទេ ខ្ញុំកាន់តែសីល៥ ។ ។

ដានីៈ ហើយលោកអី វត្តយើងចាប់ផ្តើមកសាងពីឆ្នាំណា? ហើយចាប់ផ្តើមនិមន្តលោកចូលគង់ក្នុងវត្តពីអង្កាល់ដែរ?

ស៊ីមៈ និមន្តចូលយូរហើយតាំងពី នៅចាំតែថ្ងៃទេ ត្រពាំងប្រាសាទថ្ងៃពេញបូរណី បង្កើតវត្តត្រពាំងប្រាសាទមុនគេ ហើយទំនប់ដាច់នេះថ្ងៃខែដាច់ ប្អូនកន្ទះខែ វត្តនេះ ។

ដានីៈ អត់ចាំឆ្នាំទេអ៊ំ?

ស៊ីមៈ អត់ចាំទេ ភ្លេចឆ្នាំ នឹងវត្តគេកត់ទុក ។

ដានីៈ តែមុនដំបូងលោកកូនចៅអ្នកស្រុកហ្នឹងបួសលោក ឬលោកនិមន្តមកពីខាងក្នុងមកដំបូង?

ស៊ីមៈ បងខ្ញុំជីដូនមួយ លោកមកគង់វត្តត្រពាំងប្រាសាទហ្នឹង ហើយគាត់មកហ្នឹងនៅហ្នឹង ដល់លោកសុគតហ្នឹងបានឲ្យធ្វើជាអនុគុណ ហើយសុគតទៅ ។

ដានីៈ សុគតទៅបានលោកបន្តៗមកទៀត?

ស៊ីមៈ បន្តមកទៀត បានអស់លោកទៅ បាននេះ ភ័ក្ត្រ អាអន្ទិតភ័ក្ត្រប្រមឹករាល់តែថ្ងៃនេះ ស្គាល់ភ័ក្ត្រទេ?

ដានីៈ ភ័ក្ត្រហ្នឹងគាត់បួសដែរ ហើយបានធ្វើចៅអធិការ?

ស៊ីមៈ បានធ្វើអនុគុណដែរ ។

ដានីៈ ឥឡូវសឹកមកវិញផឹកតែម្តង?

ស៊ីមៈ ប្រមឹកអួល ។

ដានីៈ កាលនៅបួស ។

ស៊ីមៈ បានធ្វើអនុគុណអស់ពីលោកតាសំ ទៅ ។ សំ ហ្នឹងបងខ្ញុំ ។

ដានីៈ អ៊ំទាក់ទងពីសាសនាផ្សេងៗទៀត មានប្រជាជនគេជឿ ឬគេកាន់ខាងសាសនាផ្សេងៗទៀត ដែលអត់?

ស៊ីមៈ យើងនេះ?

ដានីៈ បាទ!

ស៊ីមៈ ឥឡូវគេបង្កើតសាសនាឥស្លាមមួយនៅត្រពាំងប្រាសាទនេះ ។

ដានីៈ មានពួកខាងជនជាតិចាម ខាងឥស្លាមមកនៅច្រើនទេ?

ស៊ីមៈ នៅច្រើន ។

ដានីៈ ឥឡូវគេបង្កើតវត្តមួយដែរ?

ស៊ីមៈ ហ្នឹងហើយ គេបង្កើតមួយ ជាប់ផ្លូវ អមផ្លូវ ។

ដានីៈ សុំច្បាប់ពីអីដែរ?

ស៊ីមៈ ហ្នឹងហើយ ។

ដានីៈ អ៊ំយល់ឃើញយ៉ាងម៉េចដែរ អនុញ្ញាតឲ្យគេ?

ស៊ីមៈ ខ្ញុំធ្វើតាមពីលើគេសំរេចអស់ហើយ ខ្ញុំតាមគេ យើងអត់ប្រឆាំងទេ ព្រោះច្បាប់គេវត់ពីលើមកក្រោម ។

ដានីៈ តាមចិត្តយើង បងប្អូនប្រជាពលរដ្ឋពេញចិត្តឲ្យបង្កើតអីចឹងៗអត់?

ស៊ីមៈ អត់ពីណាគេពេញ បើខាងលើហៅទៅពិគ្រោះត្រូវតែមាន បើយើងបំបិទក៏មិនបានដែរ ព្រោះប្រទេសយើងវាចូលគ្រប់មជ្ឈដ្ឋានទាំងអស់ទៅហើយ ។

ដានីៈ សេរី?

ស៊ីមៈ សេរីទៅហើយ ។

ដានីៈ កាលពីជំនាន់យើងតស៊ូ មានខាងចាម បងប្អូនឥស្លាមគេតស៊ូជាមួយយើងដែរ?

ស៊ីមៈ មាន មានធ្វើទាហាន ។

ដានីៈ ចុះក្រៅពីខាងឥស្លាម មានសាសនាផ្សេងៗគេមកធ្វើវិហារ ឬអ្នកចូលសាសនាច្រើន?

ស៊ីមៈ មាន ឥស្លាម ហើយមួយនោះផ្សេងទេ ។

ដានីៈ ណាគេ?

ស៊ីមៈ មួយនៅភូមិ ចេញពីត្រពាំងប្រាសាទទៅឃុំនេះហ្នឹង ។

ដានីៈ ខាងអីគេ? យេស៊ូ?

ស៊ីមៈ អ៊ើ! យេស៊ូ ហ្នឹងដោយខ្លួនពីគ្នាទេ ២ហ្នឹង កើត២ ។

ដានីៈ បង្កើតឥស្លាមមួយ យេស៊ូមួយ ។

ស៊ីមៈ យេស៊ូមួយ ។

ដានីៈ តែអ្នកដែលជឿខាងយេស៊ូ, ឥស្លាម ហ្នឹងតិចទេ ឬក៏ច្រើនដែរ?

ស៊ីមៈ ពីដើមដូចជាស៊ុបច្រើនដែលខាងយេស៊ូ តែឥឡូវដូចអស់ អស់ឯងតែម្តង មើលទៅដូចជាគ្មានស្អី គិតតែពីរឿងសប្បាយនាំគ្នារាំច្រៀង ដល់ម៉ែឪអត់គុណបំណាច់ ម៉េចទៅ នាំតែដើរលេង ដើរតែរាំ ផឹកស៊ី ទៅអីចឹងទៅម៉េច យើងក៏ស្រួលដែរ យើងចាស់ៗគ្រាន់តែប្រាប់ទៅថាវាចំណេញឬវាខាត ហើយសប្បាយហ្នឹងម៉េច ហើយម៉ែឪបានកូនមកដោយ

សារវាសប្បាយគ្នាវា ឬមួយយ៉ាងម៉េច ។ មើលរាល់ថ្ងៃម៉ែឪខំទុកដាក់កូនចៅមានប្ដី មានប្រពន្ធ តើម្នាក់ៗអស់ប៉ុន្មាន យើងមើលផងដឹងគុណ ។

ដានី: ហើយអ៊ំទាក់ទងពីប្រវត្តិសាស្ត្រវិញ ដូចថាពួកខ្ញុំនេះមានគំនិត កំពុងតែចងក្រង កំពុងតែសរសេរស្រាវជ្រាវទាក់ទងពីប្រវត្តិសាស្ត្រនៅតំបន់អន្លង់វែង ជាពិសេសស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទយើង ។ តាមការយល់ឃើញរបស់អ៊ំ អ៊ំគិតថា ការដែរចងក្រង ការស្រាវជ្រាវប្រវត្តិសាស្ត្រទាក់ទងពីតំបន់ ដូចកន្លែងនេះយើងដាក់ថាអតីតតំបន់តស៊ូ អ៊ំគិតថាវាមានសារសំខាន់ មានប្រយោជន៍អីដែលអត់?

ស៊ឹម: មាន ត្រូវតែមាន មិនដែលអត់ ត្រូវតែមាន ពិសេសក្នុងប្រវត្តិដែលយើងដឹង យើងមានទៅវា មានកូនចៅយើងវាឃើញ ប្រវត្តិប្រទេសជាតិយ៉ាងម៉េច ។ ទឹកដីនេះកើតមកវាត្រឹមម៉ាណ ដូចខ្ញុំជំរាបម៉ិញអីចឹង កន្លែងនេះអត់មានមនុស្សនៅទេ សុទ្ធតែព្រៃខ្លា ព្រៃដំរី ហើយព្រៃភ្នំទៀតនេះ មើលគល់ឈើសុទ្ធតែដើមគគី អត់មានដើមអីទេ ។

ដានី: ដល់ពេលកូនចៅកើតក្រោយៗអត់ទាន់ទេ?

ស៊ឹម: អត់ទាន់ទេ ។

ដានី: អ៊ំមានធ្លាប់និយាយពីរឿងប្រវត្តិតស៊ូ ប្រវត្តិស្រុកទេសយើងកាលមុនផ្ទាល់ខ្លួនអីប្រាប់ដល់កូនចៅក្រោយៗដែលអត់?

ស៊ឹម: មានប្រាប់ ប្រវត្តិសាស្ត្រប្រទេសយើងនេះវាឈ្មោះប្រទេសកម្ពុជា វារងកម្មមករហូតមិនដឹងធ្វើម៉េចទេ បើយើងមិនតស៊ូត្រូវរលាយទឹកដី ត្រូវតែតស៊ូកូនចៅក្រោយ ។

ដានី: ដូចថាក្មេងក្រោយៗជឿដែលអត់ពេលដែលអ៊ំនិយាយប្រាប់ពីប្រវត្តិ កាលពីសម័យតស៊ូ សម័យសង្គ្រាមអី?

ស៊ឹម: គេជឿមានអី ។

ដានី: ជឿដែរ?

ស៊ឹម: បាទ!

ដានី: ហើយអ៊ំគិតថា គួរតែនៅក្នុងសាលារៀន ជាពិសេសនៅអន្លង់វែង នៅត្រពាំងប្រាសាទយើងគួរតែដាក់បញ្ចូលប្រវត្តិសាស្ត្រ ជាពិសេសតំបន់យើងនេះ កាលពីសម័យតស៊ូ កាលសម័យសង្គ្រាម គួរបង្រៀនឲ្យក្មេងៗជំនាន់ក្រោយគួរតែចាំ គួរតែយល់ដឹងពីតំបន់ស្រុកយើងហ្នឹងដែរ ឬក៏យ៉ាងម៉េចដែរ?

ស៊ឹម: ត្រូវមានពិគ្រោះគ្នារៀបចំ មានម៉េត, មានឌុល ខាងផ្សព្វផ្សាយរឿងទាំងអស់ហ្នឹង មានជំនាញអស់ហើយ ។

ដានី៖ មានជំនាញអស់ហើយ?

ស៊ីម៖ បាទ!

ដានី៖ បានគិតគួរទាក់ទងគាត់គួរតែបញ្ចូលប្រវត្តិសាស្ត្រហ្នឹងឲ្យចូលទៅ ក្មេងៗរៀនសូត្រដែរ?

ស៊ីម៖ ហ្នឹងហើយ ។

ដានី៖ បានពិភាក្សាជាមួយពួកគាត់ដែរ?

ស៊ីម៖ ហ្នឹងហើយ បានប្រជុំគ្នា ។

ដានី៖ ជាមួយពូសាម៉េត, ពូឌុល, ពូសារិន?

ស៊ីម៖ ជាមួយឌុល អស់ហើយ ។

ដានី៖ អ៊ំគិតថាអាហ្នឹងវាសំខាន់ដែរ?

ស៊ីម៖ ហ្នឹងហើយ សំខាន់ណាស់បើយើងមិនធ្វើអីចឹងទេវាសូន្យហើយ ខ្មែរឥឡូវស្អី បើប្រុសៗវាស្លៀកជិត បើនារីវិញវាបញ្ចេញសព្វអស់ហើយ អាគ្រក់មើលណាស់ ។

ដានី៖ អ៊ំមានបងប្អូននៅស្រុកកំណើតដែលអត់ទេសព្វថ្ងៃ?

ស៊ីម៖ អីស្រុកនោះ?

ដានី៖ បាទ! បងប្អូនបង្កើតអី?

ស៊ីម៖ បងប្អូនបង្កើតមូលគ្នាមកនេះអស់ហើយ ។

ដានី៖ មកនេះអស់ហើយអីចឹង?

ស៊ីម៖ ហ្នឹងហើយ ។

ដានី៖ បងប្អូនប៉ុន្មាននាក់ដែរអ៊ំ? បងប្អូនបង្កើត?

ស៊ីម៖ ខ្ញុំបងប្អូន៦ ស្លាប់អស់ទៅនៅ មកឥឡូវនេះនៅតែ២នាក់ ។

ដានី៖ ៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

ស៊ីម៖ ប្រុសតែ២ ។

ដានី៖ ស្រី៤ ។

ស៊ីម៖ ស្រី៤ ស្លាប់អស់ ។

ដានី៖ អ៊ំកូនទីប៉ុន្មាន?

ស៊ីម៖ ខ្ញុំពៅគេ ។

ដានី៖ អីចឹងបងៗគាត់ចាស់ហើយ?

ស៊ីម៖ ចាស់ នៅបងមួយ ។

ដានី៖ ឪពុកម្តាយអ៊ំគាត់ខូចតាំងពីអន្លង់ទៅ?

ស៊ីម៖ ខ្ញុំអត់ទាន់ផងទេឪពុក ទាន់ម្ដាយ ខ្ញុំនៅក្នុងពោះឪពុកខ្ញុំស្លាប់បាត់បានប៉ុន្មានខែបានកើត ។

ដានី៖ ឪពុកអ៊ំឈ្មោះអីទៅ?

ស៊ីម៖ ឪពុកខ្ញុំដាក់នេះ ឪពុកហើយហ្នឹង អត់ដាក់កា ណា ។

ដានី៖ សក់ ហ្នឹងឪពុកអ៊ំ?

ស៊ីម៖ បាទ!

ដានី៖ ម្ដាយឈ្មោះអីទៅ?

ស៊ីម៖ ម្ដាយឈ្មោះ ង៉ែត ។

ដានី៖ គាត់ខូចតាំងពីអង្កាល់?

ស៊ីម៖ ស្លាប់យូរហើយឪពុកខ្ញុំនោះ តាំងពីខ្ញុំនៅក្នុងពោះណោះ ។

ដានី៖ ចុះម្ដាយ?

ស៊ីម៖ ម្ដាយខ្ញុំបានធំដែលហើយ អាយុ១០ឆ្នាំហើយបានគាត់ស្លាប់ ។

ដានី៖ អីចឹងបងប្អូនអ៊ំគាត់មករស់នៅនេះជាមួយអ៊ំតាំងពីអង្កាល់មក? ឬតាំងពីសម័យតស៊ូ?

ស៊ីម៖ ទើបតែមកដែលទេ ដល់ចប់អស់ហើយបានគេមក ឃើញដី ឃើញធ្វើល្អ មិនមែនចេះទេ កាលនោះចេកមួយស្និតៗយូរអត់ចង់រួចទេ ដល់មកឃើញអីចឹងចាប់ចិត្តចង់នៅ ហើយខ្ញុំអត់ហ៊ានហៅទេ ខ្លាចគេមករកស៊ីមិនបានគេចោទថាយើងហៅគេមកឲ្យងាប់ ចិត្តឯងទេមកក៏មកទៅ ហើយខ្ញុំអត់បានទៅលេងទេស្រុក បងប្អូនមកៗ ធ្វើម៉េចឲ្យបានលុយជិះមក ទៅវិញចាំខ្ញុំឲ្យទៅវិញ ។

ដានី៖ ហើយអ៊ំកាលហ្នឹងអត់ទៅលេងស្រុកសោះ?

ស៊ីម៖ អត់រលើង តាំងពីចប់មកថ្ងៃណាសូន្យ ។

ដានី៖ សូន្យតែម្ដងអត់ដែលទៅ?

ស៊ីម៖ តាំងពីចេញមកនិយាយឲ្យចំ ។

ដានី៖ អត់ដែលទៅសោះតែម្ដង?

ស៊ីម៖ អាយុ៧០អត់ដែលទៅ ចុះបើបងប្អូនមកលេងអស់ហើយយើងទៅលេងធ្វើអីទៀត ។

ដានី៖ អត់មានបងប្អូននៅនោះ?

ស៊ីម៖ ហ្នឹងហើយ មួយមកទៅបានតែ២ឆ្នាំហ្នឹងទៅវិញ មកតាមអស់មកវិញមក មកនៅនេះរហូតទៅ យើងទៅលេងជាមួយអ្នកណា អស់រលីងអត់មានអ្នកណាមួយ ។

ដានី៖ អត់ដែលទៅធ្វើបុណ្យនៅនោះទេ?

ស៊ីម៖ អត់ទេ នៅនេះមានវត្តហើយ ខំតែកសាងនេះទៅ ។

ដានី: ហើយអ៊ំមួយទៀតទាក់ទងពីការរស់នៅរបស់បងប្អូនយើង ដូចថាកាលពីជំនាន់យើងតស៊ូការរស់នៅ របៀបថាមនោសញ្ចេតនាការរាប់អានគ្នាខុសគ្នាយ៉ាងម៉េចដែរ បន្ទាប់ពីយើងផ្តាច់ខ្លួន? ដូចថាយើងចាប់ផ្តើមពីធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលមកយើងមានផ្ទះ រស់នៅតាមក្រុមគ្រួសាររៀងៗខ្លួន អីចឹងការរាប់អានគ្នា ភាពស្និតស្នាលវាខុសគ្នាយ៉ាងម៉េចដែរកាលពីសម័យសង្គ្រាម ហើយសម័យយើងផ្តាច់ខ្លួនហើយ?

ស៊ឹម: សម័យសង្គ្រាម ហើយសម័យផ្តាច់ខ្លួនវាខុសគ្នាត្រង់ថា ម្នាក់ៗគេប្រាស់យករួចតែខ្លួន សម័យមុនគឺយើងស្រឡាញ់គ្នាណាស់ ទៅណាក៏រាប់អានគ្នា អត់បេះខឹងគ្នា អត់បេះអីទេ ជួយគ្នាទៅវិញទៅមក ។ ដល់មកសម័យឥឡូវគេប្រាស់យករួចតែខ្លួនគេទៅ យើងពិចារណាទៅឃើញហើយ មិនបាច់ខ្ញុំមានយោបល់ច្រើនទេ អាហ្នឹងវាអីចឹងហើយ ។

ដានី: សម័យឥឡូវដូចថាយើងរកស៊ីរៀងៗខ្លួន គិតរឿងមាន មិនសូវមានពេលវេលាទៅជជែកដូចកាលពីមុនយើងនៅតស៊ូជាមួយគ្នា យើងមានរបប មិនសូវគិតរឿងរកស៊ី មានពេលច្រើនហើយយើងស្រឡាញ់គ្នា ។

ស៊ឹម: យើងរកស៊ីទៅ គ្នាបានអីមករៀបចំប្រាជ្ញប្រូកអត់ទេ គិតតែពីរឿងរកសម័យឥឡូវនេះម្នាក់ៗគឺអីចឹង ។

ដានី: បើតាមយោបល់អ៊ំវិញ អ៊ំគិតថាការរស់នៅពីមុនហើយឥឡូវ ដូចថាមួយណាដែលយើងមានលក្ខណៈងាយស្រួលជាងសំរាប់ជីវិតអ៊ំ ក្រុមគ្រួសារអ៊ំវិញ?

ស៊ឹម: ឥឡូវវាស្រួលត្រង់ថាយើងរកស៊ី មិនបាច់ឡើងភ្នំក៏យើងរកស៊ីរស់ដែរ ដាំតែបន្លែ ដំណាំដាំដុះក៏ចិញ្ចឹមជីវិតបាន ហើយធ្វើមានកើតទៀត មិនមែនធ្វើមិនកើតទេ ។

ដានី: អ៊ំគិតថាឥឡូវងាយស្រួលជាង?

ស៊ឹម: វាស្រួលហើយ កាលមុនយើងទៅរកអី រកល្មមតែមួយហូបៗហ្នឹង ដែលយើងមិនទាន់ចប់មិនដឹងថ្ងៃណា យើងទៅរកធ្វើអី មួយរស់ៗនិយាយអីចឹង ។

ដានី: អ៊ំទាក់ទងពីសិទ្ធិសេរីភាពវិញ ការពីមុនហើយឥឡូវ របៀបថាសិទ្ធិសេរីភាពយើងដើរហើរការជ្រើសរើសបក្សនយោបាយវិញយ៉ាងម៉េចដែរ ខុសគ្នាយ៉ាងម៉េច?

ស៊ឹម: ខាងហ្នឹងបើយើងក្នុងការដើរហើរគ្មានអីជាងយើងមានច្បាប់ទេ បើយើងអត់ច្បាប់អាហ្នឹងយើងល្មើសច្បាប់ក៏យើងលំបាកដែរ ឲ្យតែគោរពច្បាប់យើងទៅណាក៏បាន សម័យឥឡូវ ។

ដានី: សម័យមុន សម័យសង្គ្រាម សម័យមុនសមាហរណកម្ម?.

ស៊ឹម: មុនសមាហរណកម្មក៏អីចឹងដែរ ទាល់តែមានច្បាប់ពីមេទៅហ្នឹងបានយើងទៅបាន ។

ដានី: ហើយដល់ពេលឥឡូវវិញ?

ស៊ីមៈ ឥឡូវនេះច្បាប់យើងធ្វើសំរាប់ រដ្ឋាភិបាលគេធ្វើឲ្យមក ចង់ទៅណា ។

ដានីៈ ទាក់ទងពីសេរីភាពជ្រើសរើសខាងបក្សនយោបាយវិញយ៉ាងម៉េចដែរ?

ស៊ីមៈ បក្សនយោបាយយើងវាធម្មតាហើយ យើងធ្វើយ៉ាងណាក៏រើវាមិនរួច ដាក់ស្តែងដូចជាលើកនេះ អាណត្តិទីប៉ុន្មាននេះ ។

ដានីៈ ឥឡូវអាណត្តិទី៥ ។

ស៊ីមៈ ទី៥ អាណត្តិទី៥ដែលយើងបោះឆ្នោត យើងធ្វើយ៉ាងម៉េចក៏នៅតែគេឈ្នះដដែល មិនដឹងជាសន្លឹកឆ្នោតហ្នឹងយ៉ាងម៉េច យើងពិចារណាត្រង់ហ្នឹង បានថាយើងនិយាយអីមិនល្អក៏យើងហ្នឹងអាក្រក់ទៅហើយ តែការពិតយើងចង់ឲ្យបានល្អណាស់ប្រទេសជាតិ ឲ្យវារីកចំរើន ហើយបើសិនណាអត់មានបក្សប្រឆាំងទេក៏វាសូន្យបាត់ទៅហើយខ្មែរនោះ គួរអាណោចអាធមណាស់ ។

ដានីៈ ប៉ុន្តែយើងនៅខាងស្រុកភូមិយើង ស្រុកយើងមានគណបក្សប្រឆាំងគេមានសេរីភាពធ្វើការងារអី ឬក៏មានសំឡេងភាគច្រើនដែរ?

ស៊ីមៈ មាន ក្នុងឃុំមាន ។

ដានីៈ បាទ! អ៊ំដូចជាយល់ដែលហើយ ខ្ញុំដូចជាអស់សំនួរអីដែរ អ៊ំមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំ ។

ស៊ីមៈ អត់អី ។

ដានីៈ ខ្ញុំអរគុណអ៊ំច្រើន ។

ស៊ីមៈ ត្រង់ណាដែលវាមិនត្រឹមត្រូវក៏យើងសុំបិទផង ។

ដានីៈ បាទ! ខ្ញុំអរគុណអ៊ំច្រើន ។

ស៊ីមៈ ខ្ញុំក៏អរគុណដែរ ។

**ចប់**